# វគ្គទី ៨
# ជំរុំជាយដែន
# (ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០)

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នៅពេលដែលខ្ញុំទៅធ្វើការនៅជួរមុខនោះ ជំរុំមួយចំនួន បានត្រូវបង្កើតរួចហើយ ។ ដំបូងឡើយរ.ជ.រ.ប.ខ. បានបោះជំរុំនៅលើទឹកដីខ្មែរ តាមបណ្តោយទល់ដែនខ្មែរ-ថៃ ដើម្បីហ្វឹកហ្វឺនកងទ័ព បន្ទាប់មកដើម្បីជួយធ្វើជាកន្លែងចែកចាយផ្តល់ស្បៀង ដល់ប្រជាពលរដ្ឋភៀសខ្លួនមកតាមតំបន់ទល់ដែន ។ ដោយសារចំនួនជនភៀសខ្លួននៅសម័យនោះ កាន់តែមានចំនួនកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃឥតឈប់ឈរ រ.ជ.រ.ប.ខ.ក៏បានបង្កើតជាហេដ្ឋារចនាសម្ព័ន្ធ និង ជួយសម្រួលដល់ការផ្តល់សេវាទាំងឡាយជាបន្ទាន់ ។ នៅឆ្នាំ ១៩៨២ រ.ជ.រ.ប.ខ.មានជំរុំសំខាន់ៗ៦គឺ៖ ជំរុំអំពិល ជំរុំរិទ្ធិសែន ជំរុំនងចាន់ ជំរុំអូរបុក ជំរុំណាំយឺន និង ជំរុំសុខសាន្ត ។ ក្រោយមក មានបន្ថែមជំរុំពីរទៀតគឺ៖ ជំរុំសម្លរធ្វាញ់ និង ដងរែក ។ ក៏ប៉ុន្តែ នៅឆ្នាំ ១៩៨៤-១៩៨៥ ក្រោយដែលកងទ័ពវៀតណាមបើកការវាយប្រហារក្នុងទ្រង់ទ្រាយធំមក ប្រជាពលរដ្ឋជាជនភៀសខ្លួនទាំងនោះ ក៏ត្រូវបានប្រមូលផ្តុំឲ្យមកស្នាក់នៅក្នុងជំរុំដ៏ធំមួយឈ្មោះជំរុំសាយធូ (Site 2) ។

នៅឆ្នាំ ១៩៨០ ជំរុំសាយធូមានប្រជាពលរដ្ឋចំនួន ១៧០.០០០ នាក់ស្នាក់នៅ ដែលអង្គការសហប្រជាជាតិផ្តល់លក្ខន្តិកៈជាជនជន្លៀសខ្លួន (Displaced persons) ខុសពីជនភៀសខ្លួន (Refugee) ដែលជាលក្ខន្តិកៈសម្រាប់អ្នកធ្វើដំណើរ ទៅប្រទេសទីបី ។ ជនជន្លៀសខ្លួនជាប្រជាពលរដ្ឋ ដែលត្រូវរស់នៅក្នុង

ប្រទេស មិនអាចបន្តដំណើរទៅក្រៅប្រទេសទេ ។ អង្គការសហប្រជាជាតិផ្តល់ដល់ប្រជាពលរដ្ឋទាំងនោះនូវការជួយឧបត្ថម្ភបែបសង្គ្រោះបន្ទាន់ មានម្ហូបអាហារ ការថែទាំសុខភាព និង ការអប់រំថ្នាក់មូលដ្ឋាន ឬ បឋមសិក្សា ។ ក្នុងសម័យនោះ អង្គការសហប្រជាជាតិ មានគោលនយោបាយផ្តល់ជំនួយក្នុងលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ព្រោះអង្គការនេះមិនចង់ឲ្យមានការស្នាក់នៅជាអចិន្ត្រៃយ៍ឡើយ ។ នៅសម័យនោះ រដ្ឋាភិបាលថៃធ្វើការហាមប្រាម មិនឲ្យមានការតាំងទីជំរកជាអចិន្ត្រៃយ៍នៅជិតព្រំដែនខ្មែរ-ថៃលើទឹកដីគេទេ ។ ដូច្នេះទើប រ.ជ.រ.ប.ខ. បានរៀបចំជាគោលនយោបាយ ដែលមិនគ្រាន់តែផ្តល់សន្តិសុខ សុវត្ថិភាព ម្ហូបអាហារ និង ជម្រកប៉ុណ្ណោះទេ ថែមទាំងជួយជនរួមជាតិទាំងនោះ ឲ្យលើកតម្កើង និង ពង្រឹងនូវតម្លៃប្រពៃណីជាតិ សេរីភាព និង លទ្ធិប្រជាធិបតេយ្យទៀតផង ។

## ជំរុំនៅលើទឹកដីខ្មែរ

រហូតដល់ឆ្នាំ ១៩៨៥ ប្រជាពលរដ្ឋដែលរស់នៅក្នុងជំរុំ.ជ.រ.ប.ខ.បានរស់នៅជាសហគមន៍ដែលស្នេហាសន្តិភាព មានសេរីភាពក្នុងការធ្វើដំណើរបានខ្លះៗ ព្រោះនៅពេលនោះ អ្នកទាំងនោះមិនទាន់ត្រូវគេបញ្ជូលទៅក្នុងជំរុំសាយធូនៅលើទឹកដីថៃ ដែលគេមិនអាចចេញក្រៅបរិវេណជំរុំបានឡើយ លើកលែងតែមានការអនុញ្ញាតពិសេស ។ ក៏ប៉ុន្តែនៅពេលនោះ ទោះជាគេអាចចេញចូលជំរុំដោយសេរីក៏ដោយ ក៏ភាគច្រើនមិនហ៊ានទៅឆ្ងាយ ព្រោះខ្លាចជាន់មីន លើកលែងតែប្រជាពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះ ។ ប្រជាពលរដ្ឋយើង មិនហ៊ានឆ្លងដែនចូលក្នុងទឹកដីថៃទេ ព្រោះខ្លាចតម្រួតថៃចាប់យកទៅធ្វើបាប ។ អ្នកជំរុំនាំគ្នាថែរក្សាប្រពៃណី

ធ្វើបុណ្យទានតាមទម្លាប់ ។ ចាស់ៗទៅវត្ត ឯក្មេងៗទៅសាលារៀន ។ ម្ហូបអាហារ ដូចជាអង្ករ ប្រេងឆា ត្រីប្លាធូ បន្លែស្រស់ ទឹកស្អាត សេវាសុខភាពអនាម័យ និង សេវាសង្គមកិច្ច ត្រូវបានផ្តល់ឲ្យដោយអង្គការសហប្រជាជាតិខាងជួយសង្គ្រោះ បន្ទាន់តាមជាយដែន ហៅកាត់ថាយូអិនប្រូ (UNBRO: United Nations Border Relief Operation) អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និង ទីភ្នាក់ងារស្ម័គ្រចិត្តទាំងឡាយ ដោយសារសប្បុរសធម៌របស់សហគមន៍អន្តរជាតិ ។

គ្រួសារជាច្រើនបានបញ្ជូនឪពុក ឬ បងប្រុស ឬ ប្អូនប្រុស ឬ កូនប្រុសធ្វើជាទាហានក្នុងជួររ.ជ.រ.ប.ខ. ។ ដើម្បីរក្សាអព្យាក្រឹតភាពរបស់ខ្លួន អង្គការសហប្រជាជាតិ យូអិនប្រូ មិនផ្តល់ជំនួយដល់កុមារា ឬ មនុស្សប្រុសទេ អង្គការនេះជួយតែស្ត្រី និង កុមារីតែប៉ុណ្ណោះ ។ ឯកុមារីនោះទៀត ទាល់តែមានកំពស់ចាប់ពី ១ម១០ឡើងទៅ ទើបអាចទទួលជំនួយបាន ។ នយោបាយរបស់អង្គការសហប្រជាជាតិបែបនេះ បង្កផលវិបាកយ៉ាងខ្លាំងដល់គ្រួសារណា ដែលមានសមាជិកតែភេទប្រុស ឬ ចំពោះគ្រួសារណាដែលមានសមាជិកស្រីតិច តែប្រុសច្រើនជាដើម ។ ដូច្នេះចំពោះគ្រួសារណា ដែលមានស្រីៗច្រើន ពួកគេក៏ទទួលជំនួយជាម្ហូបគ្រប់គ្រាន់ ឬ អាចដោះដូរលក់ចេញខ្លះផង ។ ខ្ញុំមិនបានដឹងថាក្រោយ មកអង្គការសហប្រជាជាតិបានធ្វើការកែសម្រួលបញ្ហានេះដោយវិធីណាទេ ។ តែខ្ញុំដឹងថាមានកូនក្មេងប្រុសៗមួយចំនួនបានចូលបន្លំធ្វើជាក្មេងស្រី នៅពេលដែលគេចុះទៅរាប់ចំនួនមនុស្សដែលត្រូវទទួលជំនួយ ។

តាមពិតទៅ ករណីបែបនេះក៏មិនមែនមានច្រើនប៉ុន្មានឡើយ ។ អ្នករស់នៅជំរុំលើទឹកដីខ្មែរ នៅពេលនោះ ធ្វើផ្ទះភាគច្រើនពីឬស្សីប្រក់ស្លឹក ដែលអង្គការសប្បុរសផ្តល់ឲ្យ ។ គ្រួសារទាហានខ្លះក៏មានផ្ទះឈើដែរ ដោយពួកគេអាចចេញទៅកាប់ឈើនៅក្រៅជំរុំបាន ។ ជាទូទៅ អ្នកជំរុំនាំគ្នាដាំបន្លែខ្លួនឯង ដើម្បីអាហាររូបត្ថម្ភ

បន្ថែមសម្រាប់គ្រួសាររបស់ពួកគេ ។

ជំរុំនីមួយៗត្រូវបានគ្រប់គ្រងដោយរដ្ឋបាលមួយ ដែលចែកចេញជាផ្នែក ដូចជា៖ ផ្នែកអនាម័យ ឬ សុខាភិបាល អប់រំ វប្បធម៌ ឬ សិល្បៈ និង សន្តិសុខ សណ្តាប់ធ្នាប់ជាដើម ។ តាមធម្មតា ជំរុំនីមួយៗមានប្រធានជំរុំម្នាក់ ដែលជាទូទៅកាន់មុខនាទីជាមេបញ្ជាការយោធាផង ។ អ្នកជំរុំ ហៅមេជំរុំថា "លោកប្រធាន" ។ លោកប្រធាន មានប្រធានរដ្ឋបាលម្នាក់ជាជំនួយការ ដែលជួយសម្របសម្រួលការងារជាមួយផ្នែកផ្សេងៗទៀត និង ជាអ្នកទាក់ទងជាមួយអង្គការសហប្រជាជាតិ ឬ អង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការនៅក្នុងជំរុំ ។ ប្រធានរដ្ឋបាលមួយចំនួនធំច្រើនចេះនិយាយភាសាបារាំង ឬ ភាសាអង់គ្លេស ឬ ខ្លះទៀតចេះនិយាយភាសាទាំងពីរតែម្តង ។ នៅជំរុំអំពិល ដែលជាបញ្ជាការដ្ឋានក.ជ.រ.ប.ខ. បានត្រូវដឹកនាំខាងផ្នែកយោធាដោយលោកឧត្តមសេនីយ ដៀន ដែល ឯផ្នែកនយោបាយដោយលោក ហ៊ីង គន្ធុន ។ តែតាមពិតទៅ លោកឧត្តមសេនីយ ដៀន ដែល ជាមេធំជាងគេនៅក្នុងជំរុំនេះ ។

នៅជំរុំអំពិល យើងមានអតីតអ្នករាំរបាំព្រះរាជទ្រព្យពីរនាក់ ម្នាក់ឈ្មោះ ស្រី មុំ ម្នាក់ទៀតឈ្មោះ សាវ៉ែ ។ ទោះជាអ្នកទាំងពីរត្រូវបានឆ្លងកាត់ការលំបាកគ្រប់យ៉ាងក្នុងរបប ប៉ុល ពត យ៉ាងណាក៏ដោយក៏សម្រស់របស់ពួកគេ មិនបានបាត់បង់ប៉ុន្មានឡើយ ។ នារីទាំងពីរបានចំណាយពេលវេលា និង ឋាមពលរបស់ពួកគេដើម្បីបង្រៀនក្មេងៗជំនាន់ក្រោយ ឲ្យចេះរាំរបាំប្រពៃណីយនេះ ដែលជាមរតកពីខ្មែរជំនាន់មុនកុំឲ្យបាត់បង់ ។ សាវ៉ែ និង ប្តីរបស់នាងឈ្មោះ វ៉ាន់ រឿន បានបង្កើតក្រុមរបាំប្រពៃណីមួយក្រុមដែលតែងតែរាំជូនភ្ញៀវសំខាន់ៗទស្សនានៅក្នុងទស្សកិច្ចរបស់ពួកគេនៅជំរុំអំពិល ។

ជំរុំនីមួយៗមានក្រុមសិល្បៈ រួមទាំងក្រុមតន្ត្រីសម័យ ឬ បូរាណ និង ក្រុម

ល្ខោនបាសាក់ផង ។ បើគ្មានភ្ញៀវសំខាន់ៗទេ ក្រុមតន្ត្រីសម័យ ឬ ល្ខោនបាសាក់តែងតែសំដែងកំដរសាធារណជននៅចុងសប្តាហ៍ ឬ នៅពេលមានពិធីពិសេសណាមួយ[196] ។ ភ្ញៀវបរទេស ដែលបានទស្សនារបាំប្រពៃណីខ្មែរតែងតែសំដែងការកោតសរសើរដល់សិល្បករ និង សិល្បការិនី អំពីទេពកោសល្យរបស់ពួកគេ ព្រមទាំងគូសបញ្ជាក់ថានយោបាយរបស់រ.ជ.រ.ប.ខ. ដែលខំថែរក្សា និង ធ្វើឲ្យវប្បធម៌ជាតិរស់ឡើងវិញនេះ ក៏ដូចជាការថែរក្សាព្រលឹងជាតិដែរ ព្រោះថាបើអស់ព្រលឹង ជីវិតយើង ក៏គ្មានន័យដែរ ។

នៅជំរុំធំៗដូចជា ឫទ្ធិសែន ឬ នងចាន់ មានផ្សារ ដែលគេអាចទិញលក់របស់របរច្រើនយ៉ាង ដោយប្រើប្រាស់ប្រាក់ថៃ (បាត) ។ ដោយមានការសហការពីអាជ្ញាធរថៃផង ទំនិញថៃត្រូវបានបញ្ចូលក្នុងទឹកដីខ្មែរនៅក្នុងជំរុំ ឬ ចូលជ្រៅទៅក្នុងទូទាំងប្រទេសផង ។ នៅទីផ្សារ គេអាចរកទិញបាននូវសាច់គោ សាច់ជ្រូក មាន់ ត្រីបន្លែ ថ្នាំពេទ្យ សម្លៀកបំពាក់ ភេសជ្ជៈ សូដា បៀរ ស្រា និង ឧបករណ៍កសិកម្មជាដើម ។ តាមពិត នៅជំរុំទាំងពីរនេះ គេអាចរកចំណូលបានជាច្រើន ដោយសារការរត់ពន្ធទំនិញពីថៃចូលក្នុងប្រទេសខ្មែរ ឬ ពីខ្មែរទៅប្រទេសថៃ ។ ជាមួយនោះគេក៏ឃើញមានហាងគុយទាវ ឬ ហាងលក់បាយ ឬ និង ហាងដូរប្រាក់ ដែលគេអាចសម្គាល់បាន ដោយសារនៅមុខផ្ទះ មានដាក់តាំងជញ្ជីងថ្លឹងមាស រង់ចាំទទួលភ្ញៀវមកដូរមាសយកប្រាក់បាត ឬ ដូរប្រាក់បាតយកមាសខ្មែរជាដើម ។ អ្នកនៅខាងក្នុងស្រុកខ្មែរអាចមកទិញទំនិញ ឬ យកអីវ៉ាន់មកលក់ រួចទិញរបស់របរ ដែលគេត្រូវការយកទៅខាងក្នុងវិញតាមវិធីរត់ពន្ធ ។ តាមចលនារបស់អ្នករត់ពន្ធនេះក៏មានបណ្តាញស៊ើបការណ៍ពីជំរុំទៅខាងក្នុង ពីខាងក្នុងមកជំរុំ សម្រាប់កិច្ចប្រតិបត្តិការយោធា ។ មេជំរុំខ្លះរកប្រាក់ចំណូលបានច្រើនដោយសារការរត់ពន្ធនេះ ដែលគេ

[196] សិល្បករដូចជា នាយសង់ស៊ីស នាយស៊ីត្រូ និង នាយជីវ៉ាន់ស៊ុយ សុទ្ធតែបានបំរើការងារនៅក្នុងជំរុំ រ.ជ.រ.ប.ខ.ទាំងអស់ ។

អាចចិញ្ចឹមទ័ពឯកជនរបស់គេបាន ដោយមិនបាច់ត្រូវការជំនួយពីរ.ជ.រ.ប.ខ. ផង ក៏មាន ។

នៅពេលលោកប្រធានជំរុំធ្វើដំណើរម្តងៗ ជាពិសេសប្រធានជំរុំនងចាន់ គេឃើញមានអង្គរក្សប្រដាប់ដោយអាវុធគ្រប់ដៃ ជិះម៉ូតូរាប់សិបគ្រឿងហែរហមយ៉ាងគគ្រឹកគគ្រេង ។ ទោះជាអ្នកជំរុំរស់នៅអាស្រ័យដោយជំនួយរបស់អង្គការសហប្រជាជាតិក៏ដោយ ក៏អ្នករត់ពន្ធបានបញ្ចូលទៅក្នុងទីផ្សារនូវសាច់ប្រាក់ចំនួនច្រើនលានបាត ។ នៅក្នុងជំរុំធំៗទាំងពីរ ក្រៅពីផ្សារ អ្នកជំរុំអាចទៅកំសាន្តនៅតាមរោងភាពយន្ត ដែលជារោងសង់ពីឫស្សីយ៉ាងធំ ។ នៅក្នុងរោងភាពយន្តនោះ គេបញ្ចាំងរឿងខ្មែរតាំងពីសម័យមុនសង្គ្រាម ដោយមានសិល្បករនិយាយបញ្ចូលសម្លេងផ្ទាល់នៅពេលបញ្ចាំងម្តងៗ ។

# ខ្ញុំរៀនវិជ្ជាត្រៃវេទ

ជាទូទៅ ប្រជាពលរដ្ឋភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ ក៏ប៉ុន្តែបន្ថែមលើនេះ ក៏មានមនុស្សមួយចំនួននៅជឿលើអារុក្ខ អារក្ស អ្នកតា អាគមអូមអាម អប្បិយជំនឿពីបូរមបូរាណ ឬ ការទស្សន៍ទាយតាមក្បួនហោរាស្រ្តផង ។ ក្នុងរយៈពេលនៃការស្នាក់អាស្រ័យនៅរបស់ខ្ញុំ ក្នុងឆ្នាំ ១៩៨២ - ១៩៨៣ នៅក្នុងជំរុំអំពិល ខ្ញុំធ្លាប់បានជួបនាយទាហានថ្នាក់កងវរសេនាតូចជាច្រើន ដែលតែងមកនិយាយលេងសំណេះសំណាលជាមួយខ្ញុំ រាល់ល្ងាចក្រោយបាយរួច ។ ក្នុងចំណោមនាយទាហានទាំងនោះ មានប្រធានកងវរសេនាតូចម្នាក់ឈ្មោះ កែវ វិបុល ធ្លាប់ចេញប្រយុទ្ធនៅសមរភូមិជាច្រើនលើកច្រើនគ្រា ដែលនាំឲ្យគេមានបទពិសោធន៍ល្អខាងយោធា ។ វិបុល មានជំនឿជឿជាក់ថាជោគជ័យរបស់គាត់នៅសមរភូមិបាន

មកដោយសារវត្ថុស័ក្តិសិទ្ធ ជាពិសេសដោយសារឫទ្ធីបារមីនៃវិជ្ជាដែលគាត់បានរៀន និង បានយកមកប្រើអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។

វិជ្ជាដែលគាត់រៀននោះ ហៅថា "វិជ្ជាត្រៃវេទ" ។ កែវ វិបុល យល់ថា "វិជ្ជាត្រៃវេទ" មានប្រភពដើមចេញពីព្រហ្មញ្ញសាសនា ។ គាត់ជឿថាវិជ្ជារបស់គាត់បានមកពីព្រះព្រហ្មមុខបួន ។ ក្នុងសម័យនោះ ខ្ញុំក៏កំពុងចង់ដឹងចង់ស្គាល់វិជ្ជាប្លែកៗបែបនេះដែរ ។ ខ្ញុំកំពុងចង់ស្វែងយល់ពីឫទ្ធិអំណាចនៃវត្ថុស័ក្តិសិទ្ធ ឬ ឫទ្ធិបារមីនៃពិភពងងឹតខ្លាំងណាស់ ។ ម្យ៉ាងទៀត ខ្ញុំក៏ចង់ដឹងអំពីវិជ្ជាត្រៃវេទនេះដែរ ។ តាមពិតទៅ ខ្ញុំមិនជឿលើអបិយជំនឿទេ ក៏ប៉ុន្តែខ្ញុំចង់ដឹងអំពីការគោរពប្រតិបត្តិរបស់អ្នកឯទៀតជាខ្លាំង ។ ដោយដឹងពីគោលជំហររបស់ខ្ញុំយ៉ាងនេះ ទើប កែវ វិបុល នាំខ្ញុំឲ្យទៅជួបលោកគ្រូរបស់គាត់ឈ្មោះ គ្រូមៀច ដែលមានតួនាទីជាទីប្រឹក្សាកងវរសេនាតូចរបស់គាត់ផង ។

នាយប់មួយនោះ ខ្ញុំក៏ទៅជួប គ្រូមៀច នៅអាស្រមរបស់គាត់ដែលសង់ឡើងពីឫស្សីប្រក់ស្លឹក ហើយជាទីដែលលោក គ្រូមៀច ស្នាក់នៅផង ។ អាស្រមរបស់លោកគ្រូ ស្ថិតនៅជាប់ពីផ្ទះប្រជាពលរដ្ឋធម្មតា និង មានភាពស្ងាត់ជ្រងំល្អណាស់ ។ គ្រូមៀច និយាយតិចៗលាយឡំនឹងទឹកមុខញញឹមជានិច្ច ។ គាត់មានសម្បុរខ្មៅ មាឌមាំ ដូចអ្នកស្រែខ្មែរសុទ្ធសាធ ។ នៅពេលដែលគាត់បង្រៀនសិស្ស ឬ ថ្វាយបង្គំ ឬ ធ្វើការស្មឹងស្មាធិ ភាវនា ឬ សមាធិ គាត់ស្លៀក និង ដណ្តប់សំពត់សពាក់ឈៀងបញ្ចេញស្មាស្តាំជានិច្ច ។ ក៏ប៉ុន្តែនៅពេលមានពិធីធំៗ គាត់អាចស្លៀកពាក់ស្បង់ចីវរពណ៌លឿងដូចព្រះសង្ឃដែរ ។ នៅពេលខ្ញុំទៅដល់គ្រូមៀច កំពុងជាប់បង្រៀនសិស្សគណរបស់គាត់ ។ នៅក្នុងបរិវេណនៃអាស្រមខាងក្រៅតូប កូនសិស្សខ្លះកំពុងហាត់រៀនវិជ្ជាម្យ៉ាង ដែលខ្ញុំមើលទៅប្រហាក់ប្រហែលនឹងវិជ្ជាគុននិយមចិន "គុងហ្វូ" ។

គ្រូមៀច ចេញមកទទួលខ្ញុំយ៉ាងរាក់ទាក់ រួចនាំខ្ញុំចូលទៅក្នុងអាស្រមរបស់គាត់ ដែលបំភ្លឺដោយពន្លឺព្រឹមៗនៃចង្កៀងប្រេងកាត និង ទៀនមួយចំនួន ។ នៅខាងក្នុងជ្រៅ ខ្ញុំឃើញបដិមារូបព្រះព្រហ្មឆ្លាក់ពីឈើជាច្រើនអង្គដាក់តាំងនៅលើអាសនៈជាច្រើនជាន់ ។ អ្វីដែលនាំឲ្យខ្ញុំភ្ញាក់ជាខ្លាំងនោះគឺ ព្រះពុទ្ធបដិមាដ៏ធំតាំងនៅលើអាសនៈខ្ពស់ជាងគេក្រោមក្លស់ពណ៌មាស ដែលដាក់បាំងផង ។ ខ្ញុំឆ្ងល់ណាស់ដែរថា ហេតុដូចម្ដេចបានជាគេយកព្រះពុទ្ធ មកលាយឡំក្នុងព្រហ្មញ្ញសាសនាយ៉ាងនេះ? តើនេះជាព្រះពុទ្ធសាសនាមហាយានទេឬ? គ្រូមៀច ពន្យល់ថា ខ្ញុំអាចមានឫទ្ធិអំណាចដ៏អស្ចារ្យ ប្រសិនបើខ្ញុំរៀនវិជ្ជាត្រៃវេទនេះសម្រេច ។ ដើម្បីឲ្យសម្រេចវិជ្ជាត្រៃវេទនេះ សិស្សត្រូវប្រតិបត្តិដូចតទៅ៖ ១. ត្រូវកាន់សីល ៥ ដូចសីល ៥ ក្នុងព្រះពុទ្ធសាសនាដែរគឺ៖ - មិនសម្លាប់ - មិនលួចទ្រព្យសម្បត្តិគេ - មិនកុហកភូតភរ - មិនលួច ឬ រំលោភប្រពន្ធកូនគេ និង មិនសេពសុរា ។ ២. មិនត្រូវគោរព ឬ ថ្វាយបង្គំអារុក្ខ អារក្ស អ្នកតា ឬ បារមីអ្វីដទៃក្រៅពីរូប ព្រះព្រហ្ម និង ព្រះពុទ្ធឡើយ ។ ចំណែករូបព្រះពុទ្ធវិញ មិនត្រូវគោរពថ្វាយបង្គំនៅទីណាដទៃពីក្នុងព្រះវិហារនៃវត្តអារាមឡើយ ។ ៣. មិនត្រូវអួតអាងប្រាប់គេពីវិជ្ជាត្រៃវេទនេះទេ ។ ក្រោយដែលបានពន្យល់ចប់សព្វគ្រប់ហើយ គ្រូមៀច ជួយអុជធូបបីសរសៃរួចឲ្យខ្ញុំក្រាបបង្គំបីដងចំពោះព្រះពុទ្ធបដិមា និង រូបព្រះព្រហ្មទាំងនោះ ។ បន្ទាប់មក គ្រូមៀច ឲ្យខ្ញុំអង្គុយដូចអ្នកស្មឹងស្មាធិភាវនា និង ប្រុងប្រៀបសូត្រ នមោតស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស - ឲ្យគ្រប់បីដង ។ បន្ទាប់មក គាត់សូត្រពាក្យបីម៉ាត់គឺ៖ ឱ អះ មះ មះ អះ ឱ ចុះឡើងៗ ហើយលោកគ្រូឲ្យខ្ញុំទន្ទេញកុំឈប់ ។ ប្រសិនបើខ្ញុំមាននិស្ស័យក្នុងវិជ្ជាត្រៃវេទ បារមីដែលជាគ្រូនឹងយកខ្ញុំជាសិស្សរបស់បារមីនោះ ។ ដូច្នេះ គ្រូមៀច មិនមែនជាគ្រូពិតប្រាកដទេ គាត់គ្រាន់តែជាអ្នកណែនាំសិស្ស ឲ្យគ្រូក្នុងផ្លូវងងឹតទទួលយកតែប៉ុណ្ណោះ ។ គ្រូពិតប្រាកដជាបារមី ដែល

មនុស្សធម្មតាមើលមិនឃើញ ។ បារមីទាំងនោះរួមមានបារមីមេទ័ពល្បីៗ អតីតព្រះមហាក្សត្រដែលគេហៅថាគ្រូតូច និង បារមីព្រះសាវ័ករបស់ព្រះពុទ្ធ ដូចជាព្រះសារីបុត្រ ព្រះមហាមោគ្គលាន ឬ ព្រះនារាយណ៍ ព្រះរាម ព្រះសេរៈ ព្រះវិស្ណុ ព្រះព្រហ្ម ឬ ហនុមានដែលគេហៅថាគ្រូធំ ។ មានតែសិស្សពិសេសមួយចំនួនតូចប៉ុណ្ណោះដែលបារមីគ្រូធំអាចទទួលយកធ្វើជាសិស្ស ។ សិស្សពិសេសនោះគឺ ជាអ្នកឧស្សាហ៍ព្យាយាម គោរពប្រណិប័តន៍បានត្រឹមត្រូវ អស់ពេលជាយូរមកហើយ ទើបអាចបានសម្រេច ។ ដោយឃើញមានការយកព្រះពុទ្ធ និង អគ្គសាវ័ករបស់ព្រះអង្គមកប្រឫកប្របល់ជាមួយនឹងពិធីដ៏ចម្លែកនេះ បានធ្វើឲ្យខ្ញុំលើកជាសំណួរសួរខ្លួនឯងថា តើកម្រិតយល់ដឹងរបស់ខ្ញុំក្នុងវិស័យព្រះពុទ្ធសាសនាមានកំរឹតត្រឹមណា? ខ្ញុំចេះតែទន្ទេញធម៌ ៖ អៈ មៈ មៈ អៈ ៖ ដោយគ្មានកំរើក ។

នៅពេលដែលភ្លើងធូបឆេះអស់មួយធូប ខ្ញុំមានអារម្មណ៍ថាមានកម្លាំងអ្វីមួយមកប៉ះដៃខ្ញុំ ។ បើខ្ញុំលែងដៃទាំងពីរ ដែលខ្ញុំកំពុងប្រណម្យនោះឲ្យឃ្លាតចេញពីគ្នា ដៃនោះហាក់ដូចអណ្តែតដោយខ្លួនឯង ហាក់ដូចជាគ្មានកម្លាំងសង្កត់ (Gravity) មកទាញឲ្យធ្លាក់ចុះក្រោមឡើយ ។ ហើយបើខ្ញុំបណ្តោយឲ្យដៃទាំងពីរមានសេរីភាព ធ្វើសកម្មភាពដោយសេរី ដៃទាំងនោះនឹងធ្វើសញ្ញាដូចជាសំពះ ឬ ប្រសិទ្ធីជាដើម ។ ខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងណាស់ចំពោះថាមពលងងឹត ដែលខ្ញុំមើលមិនឃើញនោះ ។ នៅពេលដែលវគ្គទីមួយបានបញ្ចប់ទៅនោះ គ្រូមៀច បាននិយាយមកកាន់ខ្ញុំថាល្អណាស់ លោកមាននិស្ស័យហើយៗថាឥឡូវលោកគ្រូខាងផ្នែកងងឹតទទួលលោកធ្វើជាសិស្សរួចហើយ ។ លោក គ្រូមៀច ប្រហែលជាដឹងថាគ្រូខ្ញុំជាអ្វី ឬ ជាអ្នកណា តែចំពោះខ្ញុំៗមិនបានដឹងថាជាអ្នកណាទាល់តែសោះ ។

តាំងពីថ្ងៃនោះមក ខ្ញុំបានចំណាយពេលមួយម៉ោងក្នុងមួយថ្ងៃមករៀនវិជ្ជាត្រៃវេទនេះ ។ ក្នុងរយៈពេលបីសប្តាហ៍កន្លងមក ពាក្យបីម៉ាត់ដែលខ្ញុំទន្ទេញតាំង

ពីលើកដំបូងគឺ ឱ អៈ មៈ មៈ អៈ ឱ បានប្រែជាពាក្យផ្សេងៗដែលខ្ញុំមិនយល់បាន ។ គ្រូមៀច ប្រាប់ខ្ញុំថានោះគឺជាការរៀននិយាយដូចកូនក្មេង ដែលនិយាយមិនទាន់ច្បាស់ដូច្នោះដែរ ។ បន្ទាប់មក ពាក្យដែលមិនច្បាស់ដែលខ្ញុំស្តាប់មិនបាននោះក៏ចាប់បន្លឺចេញជាសម្លេង ក ខ គ ឃ ង .... តាមអក្សរខ្មែរ.... បន្ទាប់មកទៀត ..... សម្លេង ក ក៏ចេញជាពាក្យផ្សេងៗក្នុងតួអក្សរ ក រួចពាក្យទាំងអស់ឯទៀតនៃអក្សរ ខ ...... គ ...... ឃ ....... ដែលធ្វើឲ្យខ្ញុំកាន់តែមានការចាប់អារម្មណ៍ជាទីបំផុត ។ ក្រោយដែលខ្ញុំសូត្រពាក្យដែលចេញពីមាត់ខ្ញុំដោយស្វ័យប្រវត្តិនោះ ក្រោយមកក៏ក្លាយទៅពាក្យធម៌ ...... នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស .........។ ប្រការដែលកាន់តែភ្ញាក់ផ្អើលយ៉ាងខ្លាំងនោះគឺ នៅពេលដែលខ្ញុំកំពុងបិទភ្នែកភាវនានូវពាក្យពេចន៍ ឬ បាលី ដែលចេញសម្លេងតាមមាត់ដោយស្វ័យប្រវត្តិនោះ ញាណទាំងប្រាំរបស់ខ្ញុំនៅដឹងទាំងអស់ ខ្ញុំស្តាប់ឮអ្នកនៅខាងក្រៅអាស្រមនិយាយគ្នា ឬ សម្លេងអ្វីដែលកើតមាននៅទីនោះ ។ ខ្ញុំដឹងថាដៃ ឬ ជើងខ្ញុំមានចលនាបែបណាគឺបានន័យថាខ្ញុំនៅមានស្មារតីធម្មតាទាំងអស់ ។ ដូច្នេះខ្ញុំមិនមានអារម្មណ៍ថាកម្លាំងងងឹត ឬ បារមីអ្វីមកចូលសណ្ឋិតក្នុងខ្លួនខ្ញុំ ធ្វើឲ្យខ្ញុំបាត់ស្មារតីនោះឡើយ ។ ដោយសារការឧស្សាហ៍ព្យាយាម ពាក្យបីម៉ាត់ពីដំបូងគឺ ឱ អៈ មៈមៈ អៈ ឱក៏ក្លាយជាពាក្យបាលីដែលខ្ញុំអាចសូត្របានមិនចេះចប់ ។ លើសពីនេះទៅទៀតនោះ ខ្ញុំអាចរើសមុខវិជ្ជាដែលខ្ញុំចង់បានដោយខ្លួនឯង ។ ឧទាហរណ៍ ប្រសិនបើខ្ញុំសុំរៀនបាលីការពារខ្លួន - ខ្ញុំចាប់ផ្តើមសូត្រពាក្យបីម៉ាត់ខាងដើមគឺ៖ ឱ អៈ មៈមៈ អៈ ឱ-សូត្រមិនទាន់ចប់ផង ក៏ក្លាយទៅជានមោតស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស ពុទ្ធំ ធម្មំ សង្ឃំ សព្វយន្តោ សុខី សុខោ សុខៈ សុខំ ជាដើម សារចុះសារឡើងមិនចេះចប់ ។ ខ្ញុំមិនចេះភាសាបាលីទេ តែខ្ញុំអាចបកស្រាយថា អ្វីដែលខ្ញុំសូត្រនោះគឺ ជាការសុំយកអំណាចរបស់ព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃឲ្យមកជួយឲ្យខ្ញុំបានសុខ ។

ពាក្យដែលខ្ញុំសូត្រនេះអាចផ្លាស់ប្តូរទៅពាក្យផ្សេងទៅវិញ ប្រសិនបើខ្ញុំផ្លាស់ប្តូរមុខវិជ្ជា ។ ឧទាហរណ៍ បើខ្ញុំនឹកភាវនាថាសុំរៀនវិជ្ជាគុននិយម ធម៌ដែលចេញមកមានសំនៀងជាភាសាចិនដែលខ្ញុំស្តាប់មិនបាន ឯដៃខ្ញុំក៏ចេញជាចលនាចុះឡើងទំនងដូចជាចេញក្បាច់គុនចិនដែរ ហើយប្រសិនបើខ្ញុំក្រោកឈរ ខ្ញុំក៏ចេញក្បាច់នេះទាំងជើងលោតចុះ លោតឡើងផង ។ មួយទៀតប្រសិនបើខ្ញុំចង់រៀនវិជ្ជាស្នេហ៍ ពាក្យខ្ញុំភាវនាក៏ចេញមកលាយឡំនឹងពាក្យពេចន៍ ដែលមានសំនៀងប្រហាក់ប្រហែលភាសាចាម ដែលខ្ញុំមិនយល់ទាល់តែសោះ ។ នៅប្រទេសខ្មែរយើង អស់ពេលជាច្រើនឆ្នាំមកហើយដែលគេដឹងថា ពួកចាមពូកែខាងដាក់ស្នេហ៍ ។

## ខ្ញុំចង់សាកល្បងវិជ្ជាត្រៃវេទ

កូនសិស្ស គ្រូមៀច បានសម្រេចវិជ្ជាផ្សេងៗ ។ ខ្លះចេះអង្គុយមើលជតារាសីរបស់មនុស្ស ឬ ទស្សន៍ទាយព្រឹត្តការណ៍ផ្សេងៗ ។ ខ្លះចេះមើលជម្ងឺ ចេះស្រោចទឹក ។ ក្រោយដែលបានរៀនវិជ្ជាត្រៃវេទនេះ ខ្ញុំហាក់ដូចជាមិនចេះខ្លាច នឹកថាមានគេថែរក្សាការពារ ក៏ប៉ុន្តែខ្ញុំមិនដឹងថាចេះខាងអ្វីពិតប្រាកដឡើយ ។ នៅពេលដែលមានទាហានមួយក្រុម ក្រោមបញ្ជារបស់ តាមុាំង បានរាយការណ៍ថាក្រុមគេបានកាន់កាប់តំបន់ប្រាសាទបន្ទាយឆ្មារ នៅស្រុកថ្មពួក ក្នុងខេត្តបន្ទាយមានជ័យ ខ្ញុំស្ម័គ្រចិត្តទៅតាម តាមុាំង ទៅធ្វើទស្សនកិច្ចមួយថ្ងៃមួយយប់នៅបន្ទាយឆ្មារ ។ ខ្ញុំអាងលើ គ្រូមៀច ដែលខ្ញុំនឹកថា អាចការពារពួកយើងបាន ប្រសិនបើមានអាសន្នអ្វី ទើបនាំគាត់ទៅរួមដំណើរជាមួយ ។ តែសំណាងយើងមាន ពួកយើងពុំមានជួបនឹងឧបសគ្គអ្វីឡើយ ទាំងទៅទាំងមក ។ ដូច្នេះ ខ្ញុំក៏ពុំបានសាកល្បងវិជ្ជាត្រៃវេទរបស់យើងថាតើស័ក្តសិទ្ធដល់កំរិតណាទេ ។

# អាងវិជ្ជាត្រៃវេទ នាំគ្នាទៅគាស់កំណប់

ជាច្រើនខែក្រោយមក លោក កេត រ៉េត (អតីតវរសេនីយឯកកងទ័ពសាធារណរដ្ឋ លន់ នល់) ដែលខ្ញុំហៅឈ្មោះគាត់ជាសាមញ្ញថា "តារ៉េត" ជាសិស្សរបស់គ្រូមៀច ដែរ បានមកប្រាប់ខ្ញុំថា អង្គរក្សរបស់គាត់ម្នាក់ដែលចេះវិជ្ជាត្រៃវេទ បានអង្គុយធម៌ ហើយឃើញខ្មោចមិត្តគេពីរនាក់ មកពន្យល់ឲ្យទៅគាស់កំណប់ចំនួនបីបាវ ដែលកាលនៅរស់ ពួកគេទាំងបីនាក់បានកប់នៅក្បែរប្រាសាទស្តុកកក់ធំ ក្នុងសម័យខ្មែរក្រហម ។ នៅសម័យនោះ ប្រាសាទនេះនៅលើទឹកដីខ្មែរ ។ អង្គរក្សនោះធានាថាគេស្គាល់ទីកន្លែងច្បាស់លាស់ណាស់ ព្រោះគេធ្លាប់ចូលរួមក្នុងការកប់លាក់កំណប់នោះជាមួយមិត្តពីរនាក់ទៀត ដែលស្លាប់ទៅហើយដោយសារក្បត់ទៅលួចគាស់តែរៀងៗខ្លួនខុសពីពាក្យសម្បថ ។ អ្វីដែលអង្គរក្សនោះចង់បានគឺសុំឲ្យពួកយើងជួយសុំច្បាប់ថៃ ឲ្យផ្តល់មធ្យោបាយដឹកជញ្ជូន(រថយន្ត Pick up) និង ច្បាប់ឆ្លងកាត់ទឹកដីថៃ ដើម្បីធ្វើដំណើរពីជំរុំអំពិល ទៅជំរុំរិទ្ធិសែន ។ ដូច្នេះខ្ញុំក៏សុខចិត្តធ្វើតាមគឺ ស្នើសុំឲ្យទាហានប្រចាំការថៃ នាំពួកយើងតាមរថយន្តឆ្ពោះទៅទីនោះ ។

នៅពេលទៅដល់ជំរុំរិទ្ធិសែន តារ៉េត ចេញទៅជួបលោក ជា ឈុត ប្រធានជំរុំនងចាន់ ដែលបានមកជ្រកនៅបណ្តោះអាសន្នក្នុងជំរុំរិទ្ធិសែននៅពេលនោះ រួចបន្ទាប់មក តារ៉េត ក៏ចេញទៅជួបលោក លីវ ណេ ប្រធានជំរុំរិទ្ធិសែនទៀត ។ មេជំរុំទាំងពីរ យល់ព្រមតាមសំណើរបស់យើងភ្លាម ។ យើងទាំងអស់គ្នាសុទ្ធតែជឿស៊ុបថា នឹងសម្រេចតាមគោលបំណងគឺ ប្រាកដជាគាស់បានកំណប់ដ៏មានតម្លៃមិនខានឡើយ ។ ទោះបីជាពួកយើងមិនទាន់ឃើញកំណប់យ៉ាងណាក៏ដោយ ក៏ពួកយើងមានផែនការបែងចែកកំណប់នោះជាបីចំណែកដែរគឺ ១/៣ ជូនមេជំរុំទាំងពីរ

១/៣ ជូន តារ៉េត និង កូនចៅជាអង្គរក្ស ដែលបានកប់កំណប់ និង កម្លាំងឯទៀតរបស់គាត់ ចំណែកនៅសល់ ១/៣ ជូន រ.ជ.រ.ប.ខ. ដែលមានខ្ញុំជាតំណាងទុកយកមកចំណាយក្នុងការតស៊ូរំដោះជាតិ ។ ទាំងអស់គ្នាសុខចិត្តឲ្យខ្ញុំជាតំណាងផ្ទាល់របស់ប្រធានរ.ជ.រ.ប.ខ. ដែលមានអំណាចពេញទីក្នុងការបែងចែកកំណប់នោះទៅអង្គភាពនានារបស់យើង ។ លោក ជា ឈុត និង លីវ ណេ បាននាំទាហានជាង ១០០ នាក់ ដើម្បីរក្សាសន្តិសុខផង ដើម្បីជាកម្លាំងក្នុងការគាស់រំលើងដំបូកមួយផង ។ នៅពេលដែលគេប្រាប់ថា កំណប់នោះស្ថិតនៅក្នុងដំបូកមួយកំពស់ប្រមាណ ១ម២០ លោក ជា ឈុត បញ្ជាឲ្យគាស់រំលើងដំបូកនោះភ្លាម ។ នៅពេលដែលពួកទាហានចាប់ផ្តើមជីករំលើងដំបូកនោះ អ្នកចេះវិជ្ជាត្រៃវេទម្នាក់ក៏ផ្តួចផ្តើមគំនិតអង្គុយសមាធិប្រើវិជ្ជាភ្នែកទិព្វ ដើម្បីពិនិត្យមើលតាមផ្លូវងងឹតនូវការប្រព្រឹត្តិទៅនៃការគាស់កំណប់នេះ ។ នៅពេលដែលពួកទាហាន បានគាស់រំលើងអស់ដំបូកមួយរួចទៅហើយៗបានជីកដីជម្រៅជាងពីរម៉ែត្រទៀតផងនោះ ក៏ពួកយើងនៅតែមិនឃើញនូវកំណប់ ដែលយើងសង្ឃឹមថាមានតម្លៃខ្ពស់នោះសោះ ។

ពួកអ្នកជីកគាស់កកាយនោះ ធ្វើការតាំងពីម៉ោងបីរសៀល និង ពេញមួយយប់ រហូតដល់ភ្លឺ ម៉ោងប្រាំព្រឹក ក៏នៅតែរកមិនឃើញ ។ ពួកគេអស់កម្លាំងហេវហត់ណាស់ ។ ឯខ្ញុំក៏ទ្រាំចាំមើលអស់មួយយប់ ក្រោមទឹកសន្សើម ដោយមិនហ៊ានចេញទៅណាឡើយ ។ នៅពេលខ្ញុំសួរអ្នកអង្គុយសមាធិនោះថា ហេតុអ្វីបានជាពួកយើងរកកំណប់នោះមិនឃើញ ។ អ្នកចេះវិជ្ជាត្រៃវេទនោះ និយាយថា បារមីការពារទឹកដីតំបន់នេះគេមិនសប្បាយចិត្តជាមួយពួកយើង ព្រោះយើងអាងអំណាចជាអ្នកធំអាងកម្លាំង ហើយចូលមកគាស់កកាយ ដោយមិនបានសុំម្ចាស់ទឹកម្ចាស់ដីជាមុនមុននឹងគាស់រំលើងដំបូករបស់គេ ។ អ្នកនោះបន្តទៀតថា ម្ចាស់ទឹកម្ចាស់ដីគេមិនហ៊ានធ្វើអ្វីពួកយើងទេ ព្រោះយើងសុទ្ធតែមនុស្សអ្នកមានអំណាចតែបារមីបាននាំ

កំណាប់ទៅកន្លែងដទៃទៀតផុតទៅហើយ ។

ព្រឹកនោះ តារ៉េត បាននាំខ្ញុំចេញពីកន្លែងគាស់រំលើង ទៅជួបអ្នកចូលរូបម្នាក់នៅក្នុងតំបន់ ដែលមានមនុស្សអ៊ូអរក្នុងភូមិជនភៀសខ្លួនឈ្មោះភូមិព្រៃចាន់ ។ អ្នកចូលរូបនោះ ជាស្ត្រីក្នុងអាយុ ៣០ ឆ្នាំប្លាយ ។ បើគ្រាន់តែក្រឡេកមើលភ្លាម គេអាចដឹងបានថាស្ត្រីនោះ ជាមនុស្សទីក្រុងបែបស៊ីវិល័យ មិនទំនងជាអ្នកចូលរូបអ្វីទេ ។ មែនទែនទៅ នេះជាលើកទីមួយដែលខ្ញុំបានជួប និង សកម្មភាពនៃអបិយជំនឿបែបនេះ ។ យើងបានរៀបចំទៀនធូប និង របស់របរជាអណ្តាប់តាមទម្លាប់ជូនទៅស្ត្រីនោះ ។ នៅពេលដែលគាត់អុជធូបរួច និង ថ្វាយបង្គំរួចហើយ ភ្លាមនោះខ្លួនស្ត្រីនោះហាក់ដូចជាកន្ត្រាក់ញ័រ ដែលជាសញ្ញាថា មានបារមីមកចូលក្នុងរូបរបស់គាត់ ។ បន្ទាប់មក សម្លេងខ្សាវៗ បានបន្លឺចេញតាមមាត់ស្ត្រីនោះ ។ បារមីបានបង្ហាញខ្លួនតាមពាក្យសំដីថា "ចៅៗមានការអ្វី? តាជាលោកតាឥសី ចៅមានការអ្វីនិយាយភ្លាមៗមក ព្រោះតារវល់ខ្លាំងណាស់ - មានការអ្វីនិយាយមក-តាប្រញាប់ទៅកូឡាលំពួរ ទៅមើលគេប្រជុំអាស៊ានអំពីកម្ពុជា" ។ តារ៉េតជំរាបបារមីអំពីរឿងរ៉ាវរបស់ពួកយើង នៅពេលដែលខ្ញុំកំពុងលួចសើចក្នុងចិត្ត មិនហ៊ានឲ្យគេឃើញពីអាការៈខាងក្រៅ ដោយបានឮលោកតានិយាយពីការប្រជុំអាស៊ាន ។ ខ្ញុំនឹកក្នុងចិត្តថាលោកតា គួរតែរួមដំណើរជាមួយគណៈប្រតិភូរបស់យើងទៅចូលរួមប្រជុំអាស៊ាន ព្រោះថាបញ្ហាកម្ពុជា បានត្រូវប្រកូកប្រកាសទៅដល់ពិភពងងឹតទៅហើយ ។ តែជាការគួរឲ្យភ្ញាក់ផ្អើលចំពោះខ្ញុំគឺ អ្វីដែលលោកតាមហាឥសីប្រាប់យើងនៅពេលនេះ ក៏ដូចគ្នានឹងអ្វីដែលអ្នកអង្គុយធម៌គ្រែវេទប្រាប់ពួកយើងពេលមុននោះបន្តិចដែរ ។

នៅទីបញ្ចប់ពួកយើងក៏បោះបង់ចោលនូវការស្វែងរកកំណាប់នោះទៅ ដោយមានការខកចិត្តយ៉ាងខ្លាំង ។ ខ្ញុំខកចិត្តព្រោះមិនឃើញថាវិជ្ជាគ្រែវេទមានប្រសិទ្ធ

ភាពជាក់ស្តែងអាចជួយឲ្យពួកយើងរកបាននូវកំណប់ ដែលយើងចង់បាននោះឡើយ ។ ក៏ប៉ុន្តែ គ្រូមៀច ពន្យល់ថាប្រសិទ្ធភាពនៃវិជ្ជាត្រៃវេទគឺ អាស្រ័យលើការគោរពប្រណិប័តន៍វិន័យបានជាប់លាប់ឬទេ? ជាពិសេសការកាន់សីលប្រាំ ។ បើយើងមិនបានរក្សាសីលឲ្យបានត្រឹមត្រូវទេ វិជ្ជាត្រៃវេទមិនអាចជួយយើងបានទេ ។ ចំពោះខ្ញុំ តាមពិតទៅ ខ្ញុំមានការលំបាកក្នុងការរក្សាសីលឲ្យបានគ្រប់ទាំងប្រាំនោះណាស់ ។ បើខ្ញុំអាចកាន់បាន ៤ ការវៀរចាកសុរាជាការពិបាក ។ ខ្ញុំមិនមែនជាអ្នកប្រមឹក ឈប់ទទួលទានស្រាមិនបាននោះទេ ។ តែខ្ញុំត្រូវការទទួលទានខ្លះៗនៅពេលជួបជុំជាមួយអង្គទូតជាញឹកញាប់ តាមការអញ្ជើញរបស់ស្ថានទូតនីមួយៗ ក្នុងពិធីបុណ្យប្រចាំប្រទេសជាមិត្តនោះ ។ ចំណុចល្អអំពីវិជ្ជាត្រៃវេទគឺ វិជ្ជានេះបានដាស់តឿនខ្ញុំថាមនុស្សយើង រស់នៅជាមួយពិភពមួយទៀត ដែលងងឹតយើងមើលមិនឃើញ ។ ក្នុងឋានៈជាអ្នកកាន់ព្រះពុទ្ធសាសនា ខ្ញុំបានរៀនសូត្រ ដឹងថាឋានព្រហ្មជាឋានខ្ពស់ជាងគេ មុននឹងឡើងដល់ឋានព្រះនិព្វាន ។ ព្រះភ័ក្ត្រនីមួយៗនៃព្រះព្រហ្មជាតំណាងធម៌មេត្តា ករុណា មុទិតា និង ឧបេក្ខា ដែលអាចយោងមនុស្សឲ្យឡើងទៅជាមនុស្សប្រសើរឧត្តុង្គឧត្តមបំផុតនៅក្នុងលោក ។ នៅទសវត្សរ៍ឆ្នាំ ១៩៩០ នៅពេលដែលខ្ញុំទទួលភារកិច្ចសរសេរអំពីកម្មវិធី និង គោលនយោបាយរបស់គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ខ្ញុំបានយកធម៌ទាំងបួននេះជាមូលដ្ឋានដ៏សំខាន់នៃទស្សនវិជ្ជាក្នុងការដឹកនាំ ក៏ដូចជាសេរីភាពនៃឯកត្តបុគ្គល សិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យរបស់គណបក្សយើងដែរ ។

# នៅជុំវិញសាយធូ

ក្រោយពេលដែលកងទ័ពវៀតណាម និង កងទ័ព ហេង សំរិន (នៅសម័យនោះ យើងតែងនិយមហៅទ័ពរដ្ឋកម្ពុជាថាកងទ័ព ហេង សំរិន) បានវាយបោស

សំអាតជំរុំនៅតាមទល់ដែនអស់ក្នុងឆ្នាំ ១៩៨៤-១៩៨៥ មក ជនជន្លៀសខ្លួនខ្មែរត្រូវបានប្រមូលផ្តុំនៅជំរុំសាយធូនៅក្នុងទឹកដីថៃ ។ នៅពេលនោះ ស្ថានភាពរបស់ជនរួមជាតិទាំងនេះក៏មានការផ្លាស់ប្តូរដែរ ។ ពួកគេត្រូវរស់នៅក្នុងជំរុំដ៏ធំមួយដែលមានរបងលួសបន្លាហ៊ុំព័ទ្ធ និង ដោយមានទាហានអាវខ្មៅថៃ "សឿប្រាន" "ខ្លាព្រាន" យាមកាមយ៉ាងតឹងរឹងផង ។ ក្រោយបន្តិចមក អង្គភាព "ខ្លាព្រាន" នេះបានដូរឈ្មោះមកថា "កងអង្គភាពការពារជនជន្លៀសខ្លួន" "Displaced Persons Protection Unit (DPPU) ឬ ហៅកាត់ឌីភីភីយូ ។ អង្គការសហប្រជាជាតិយូអិនប្រូ បន្តនយោបាយផ្តល់ជំនួយសង្គ្រោះបន្ទាន់ដដែល ដូចកាលនៅលើទឹកដីខ្មែរដែរ គឺ មិនមាននយោបាយជួយក្នុងលក្ខណៈ ឲ្យមានទីជំរកជាអចិន្ត្រៃយ៍នោះឡើយ ។ ក៏ប៉ុន្តែទោះជាយើងយល់នូវនយោបាយរបស់យូអិនប្រូ និង រាជរដ្ឋាភិបាលថៃក្នុងការផ្តល់តែជំនួយសង្គ្រោះបន្ទាន់យ៉ាងណាក្តី ក៏ពួកយើងអ្នកទទួលខុសត្រូវខ្មែរនៅតែមានចេតនាផ្តល់ដល់ជនរួមជាតិទាំងនោះ នូវកម្មវិធីអភិវឌ្ឍន៍ដែលអាចធ្វើពួកគេឲ្យទៅជាពលរដ្ឋល្អ និង ប្រកបដោយការទទួលខុសត្រូវ នាពេលអនាគតក្នុងប្រទេសមួយដែលសេរី និង កាន់លទ្ធិប្រជាធិបតេយ្យ ។

នៅពេលដែលត្រូវប្រមូលមកនៅផ្តុំគ្នាក្នុងជំរុំសាយធូតែមួយក៏ដោយ ក៏ប្រធានជំរុំនានា នៅតែមានការបែកបាក់គ្នាជាពីរក្រុមដដែល ទោះបីជាលោកតាសឺន សាន ព្យាយាមធ្វើការបង្រួបបង្រួម និង ទោះបីជាលោកតាប្រធានបានតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ.យ៉ាងណាក៏ដោយ ។ អ្នកដឹកនាំជំរុំអំពិល និង ជំរុំរិទ្ធីសែន នៅតែគាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដដែល ព្រោះពួកគេយល់ថា ពួកគេនៅជួរមុខត្រូវតែជួយគាំទ្រកងទ័ព ។ នៅថ្ងៃទី ១៧ ធ្នូ ១៩៨៧ នៅពេលដែលលោកតា សឺន សានទៅធ្វើទស្សនកិច្ចនៅជំរុំសាយធូ មានបើកអង្គប្រជុំមួយដែលមានលោកឧត្តម

សេនីយ សក់ ស៊ុតសាខន លោកឧត្តមសេនីយ ដៀន ដែល និង លោក នាង ជិនហាន ផង រួមទាំងអ្នកទទួលខុសត្រូវឯទៀតចូលរួម ដើម្បីពិភាក្សាអំពីការរៀបចំស្ថាប័នស៊ីវិលនានា ជាពិសេសការបង្កើតរដ្ឋបាលកណ្តាលមួយនៅសាយធូ ។ នៅពេលប្រជុំនោះ លោកឧត្តមសេនីយ ដៀន ដែល និង អ្នកគាំទ្ររបស់គាត់ នៅតែទទូចសុំឲ្យរដ្ឋបាលសាយធូស្ថិតនៅក្រោមអំណាចរបស់កងទ័ព ក៏ប៉ុន្តែ នៅទីបំផុតលោកឧត្តមសេនីយសុខចិត្តទទួលយកតាមសេចក្តីសម្រេចរបស់ប្រធាន ។ សូមបញ្ជាក់ថា នៅក្នុងអង្គប្រជុំនោះមានការជជែកគ្នាយ៉ាងខ្លាំងរវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ ដៀន ដែល ដោយសារលោក ដៀន ដែល បានចោទលោកតា សឺន សាន ថាមានបំណងចង់លក់ដីស្ថានទូតខ្មែរនៅឯទីក្រុងតូក្យូនៃប្រទេសជប៉ុន ។ តាមពិតទៅ លោកតាប្រធានមិនបានលក់ដីនោះ ដូចការចោទប្រកាន់ទេ គ្រាន់តែចង់ជួលតាមរបៀប (Leasing)គឺ ជួលសិនមុននឹងលក់ ។

នៅខែ មករា ១៩៨៨ លោកតា សឺន សាន បានតែងតាំងខ្ញុំឲ្យធ្វើជាតំណាងរបស់គាត់ទទួលបន្ទុកខាងរដ្ឋបាលស៊ីវិល[197] ។ ក្នុងឋានៈនេះ ដោយឆ្លៀតឱកាស ដែលហាក់ដូចមានឯកភាពផ្ទៃក្នុងដ៏កម្រនាពេលនោះ ខ្ញុំក៏បានកោះអញ្ជើញប្រធានជំរុំទាំងអស់មកជួបជុំគ្នា ដើម្បីធ្វើការបោះឆ្នោតរើសគណៈកម្មាធិការកណ្តាលមួយ ដើម្បីសម្របសម្រួលសកម្មភាពទាំងអស់នៅក្នុងជំរុំសាយធូទាំងមូល ។ សូមបញ្ជាក់ថាប្រធានជំរុំទាំងអស់ នៅតែរក្សាអត្តសញ្ញាណរបស់ខ្លួន និងគ្រប់គ្រងប្រជាពលរដ្ឋរបស់ខ្លួនដែលធ្លាប់រស់នៅក្នុងជំរុំលើទឹកដីខ្មែរ ទោះជាត្រូវបានប្រមូលមករស់នៅក្នុងជំរុំសាយធូយ៉ាងណាក៏ដោយ ។ ម្យ៉ាងទៀត ទាំងយូអិនប្រូ ទាំងអាជ្ញាធរថៃ ក៏មិនជ្រៀតជ្រែកក្នុងការរៀបចំណាមួយរបស់ខាងភាគីខ្មែរដែរនៅសម័យនោះ ។ លោក ធូ ថុន និង លោក ង៉ែត សូផុន ប្រធានជំរុំរិទ្ធិសែន និង

---

[197] Son Sann, Khmer Peoples's National Liberation Front, Décision no.88-01/FNL, Fait le 31 Janvier 1988.

ប្រធានជំរុំអំពិល ដែលជាអ្នកគាំទ្រដ៏សំខាន់របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏បានចូលរួមក្នុងការបោះឆ្នោតនោះដែរ ។ តាមរយៈការបោះឆ្នោតនេះ លោក ឡាយ ខែក ត្រូវបានជាប់ឆ្នោតជាប្រធានគណៈកម្មាធិការនៃរដ្ឋបាលកណ្តាលរបស់ជំរុំសាយធូទាំងមូល ។ ភ្លាមៗនោះ ខ្ញុំបានទទួលជោគជ័យយ៉ាងធំក្នុងការបង្រួបបង្រួមមេជំរុំទាំងអស់ នៅក្នុងគណៈកម្មាធិការកណ្តាលនេះ ។

## ការងារផ្នែកសិទ្ធិមនុស្ស

ក្នុងប៉ុន្មានឆ្នាំកន្លងមកមុននេះ ទាហានមួយចំនួននៃក.ជ.រ.ប.ខ.បានត្រូវទទួលការចោទប្រកាន់ថាបានរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដែលជាអំពើផ្ទុយពីគោលការណ៍របស់រ.ជ.រ.ប.ខ. ដែលត្រូវសង្គ្រោះ បំរើ ការពារប្រជាពលរដ្ឋខ្មែរ ។ តាមពិតទៅ ទាហានទាំងនោះភាគច្រើន ជាក្រុមដែលគ្រាន់តែយកឈ្មោះរ.ជ.រ.ប.ខ.មកប្រើ ក៏ប៉ុន្តែរស់នៅរបៀបឯករាជ្យម្ចាស់ការខ្លួនគេ តាមរយៈសកម្មភាពរត់ពន្ធ និង ការគាបសង្កត់យ៉ាងព្រៃផ្សៃទៅលើជនភៀសខ្លួនដែលរត់មកតំបន់ជាយដែនខ្មែរ-ថៃ ។ ដោយសារមានការចោទប្រកាន់បែបនេះ អាជ្ញាធរយោធាថៃ បានដកមេដឹកនាំរ.ជ.រ.ប.ខ.បួននាក់ចេញពីតំបន់ទល់ដែន នៅខែ កុម្ភៈ ១៩៨៨ គឺ លោកឧត្តមសេនីយ ដៀន ដែល លោក ហ៊ីង គន្ធុន លោក ជា ឈុត និង លោក លីវ ណេ ។ ដោយមិនបានឲ្យថ្នាក់ដឹកនាំជាន់ខ្ពស់រ.ជ.រ.ប.ខ.ដឹងអ្វីទាំងអស់ អ្នកទាំងបួននាក់នោះ ត្រូវបញ្ជូនតាមឧទ្ធម្ភាគចក្រ មកបន្ទាយកងទ័ពពិសេសថៃនៅខេត្តលុបបូរី ។ ទំនងប្រហែលគ្រាន់តែជានុយ ដើម្បីទាក់ទាញសហសេវិកពីរនាក់ទៀតឲ្យមកជាមួយ លោកឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ីង គន្ធុន ត្រូវបានដោះលែងឲ្យវិលត្រឡប់ទៅកន្លែងដើមវិញ ក្រោយដែលបានសម្រាកនៅក្នុងបន្ទាយកងទ័ពពិសេសក្នុងផ្ទះសុវត្ថិភាពអស់រយៈពេល ២៤ ម៉ោង ។ ចំណែក

លោក ជា ឈុត និង លីវ ណោ ត្រូវបន្តស្ថិតនៅក្នុងបន្ទាយលុបបូរី អស់រយៈពេលមួយសប្តាហ៍ មុននឹងត្រូវបញ្ជូនមកឲ្យរស់នៅជាមួយពួកយើងឯទីក្រុងបាងកក ។

នៅជំរុំសាយធូមានតែជនស៊ីវិលទេ ដែលអាចស្នាក់នៅបានគ្មានទាហានណាម្នាក់អាចនៅទីនោះបានឡើយ ។ ដើម្បីជៀសវាងកុំឲ្យមានអំពើរំលោភសិទ្ធិមនុស្ស ដូចដែលត្រូវបានចោទប្រកាន់ក្នុងពេលកន្លងមក រ.ជ.រ.ប.ខ.ក៏បានផ្តួចផ្តើមគំនិតធ្វើការអប់រំ និង បង្កើតស្ថាប័នការពារសិទ្ធិមនុស្សនេះឡើង ។ ខ្ញុំនឹកថានៅសម័យនោះ ក្នុងចំណោមចលនាតស៊ូតាមជាយដែន រ.ជ.រ.ប.ខ.ប្រហែលជាចលនាតស៊ូខ្មែរតែមួយគត់ដែលបានគិតគូរអំពីបញ្ហាសិទ្ធិមនុស្សនេះ ។ ដំបូងឡើងពួកយើងបង្កើតការិយាល័យសិទ្ធិមនុស្សមួយនៅក្នុងជំរុំ ដែលមានភារកិច្ចរាយការណ៍ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ រាល់អំពើរំលោភសិទ្ធិមនុស្សដែលកើតមាន និងផ្សព្វផ្សាយឯកសារ ឬ សៀវភៅ ព្រមទាំងធ្វើការអប់រំដល់ជនស៊ីវិល និង ទាហានឲ្យយល់ដឹងអំពីសិទ្ធិមនុស្ស ។ ដោយសារការបង្កើតការិយាល័យសិទ្ធិមនុស្សនេះទើបអង្គការយូអិនប្រូ បានផ្តល់ថវិកាមួយចំនួន ដើម្បីឲ្យពួកយើងបកប្រែ និងបោះពុម្ពផ្សាយជាកូនសៀវភៅរាប់ពាន់ក្បាលស្តីពីសិទ្ធិមនុស្ស ។ ខ្ញុំជឿថា ខ្ញុំជាខ្មែរម្នាក់ ក្នុងសម័យក្រោយរបបប្រល័យពូជសាសន៍ ក្នុងចំណោមខ្មែរមួយចំនួនតូចដែលបានធ្វើការបកប្រែនូវសេចក្តីប្រកាសសកលនៃសិទ្ធិមនុស្ស ពីភាសាអង់គ្លេសមកភាសាខ្មែរ ។ យើងបានបញ្ជូនមកក្នុងស្រុកនូវសៀវភៅ និង ឯកសារផ្សេងៗទៀតស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានបងប្អូនមួយចំនួន យកមកធ្វើជាដើមទុនបង្កើតអង្គការក្រៅរដ្ឋាភិបាលខាងសិទ្ធិមនុស្សរហូតដល់សព្វថ្ងៃ ។

លើសនេះទៅទៀត ដោយសារមានមិត្តភក្តិជាច្រើននៅសភាអឺរ៉ុប ជាពិសេស មានជំនួយពីព្រះអង្គម្ចាស់នៃប្រទេសអូទ្រីស ព្រះនាម អុតតូ វ៉ុន ហាប្សបួរ (Otto Von Habsburg) រ.ជ.រ.ប.ខ. បានរៀបចំសន្និទអន្តរជាតិមួយក្រោមប្រធាន

បទ "សិទ្ធិមនុស្សដើម្បីកម្ពុជា" នៅទីក្រុងស្ត្រាប្ទួរ នៃប្រទេសបារាំង ពីថ្ងៃទី ១២ ទៅ ១៤ ធ្នូ ១៩៨៨ ។

គោលបំណងនៃសន្និសីទអន្តរជាតិនោះគឺ ជំរាបសហគមន៍អន្តរជាតិអំពីសភាពការណ៍សិទ្ធិមនុស្សនៅកម្ពុជា បន្ទាប់ពីរបប ប៉ុល ពត និង បន្ទាប់ពីការលុកលុយរបស់កងទ័ពវៀតណាម ។ នៅក្នុងសន្និសីទនោះ លោកតា សឺន សាន[198] ក្រៅពីរៀបរាប់ពីស្ថានភាពនៃការគោរពសិទ្ធិមនុស្សនៅក្នុងជំរុំ បានវាយប្រហារយ៉ាងខ្លាំងទៅលើអំពើរំលោភរបស់កងទ័ពវៀតណាម និង របបរដ្ឋកម្ពុជានៅភ្នំពេញ ។ ចំពោះការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សនៅក្នុងជួរ ร.ជ.រ.ប.ខ. លោកតា សឺន សាន ប្រកាសថា រ.ជ.រ.ប.ខ. បើកទ្វារចំហរឲ្យមានការស៊ើបអង្កេតជានិច្ចចំពោះរាល់សកម្មភាពរំលោភសិទ្ធិមនុស្ស ដោយអង្គការអន្តរជាតិនានាខាងផ្នែកសិទ្ធិមនុស្ស ។ លោកតាថ្លែងសូមឲ្យអង្គការទាំងនោះ មកជួយបោសសំអាតអំពើខុសឆ្គងទាំងឡាយណា ដែលអាចកើតមាននៅក្នុងរ.ជ.រ.ប.ខ. ។ ក៏ប៉ុន្តែលោកតាត្អូញត្អែរ និង តវ៉ាថា "រហូតមកដល់ពេលនេះ គេបោសសំអាតតែមួយជ្រុងតុ ខ្ញុំសូមឲ្យគេសំអាតតុទាំងមូល គ្រប់ជ្រុងទាំងអស់" ។ តាមពិតទៅ លោកតាប្រធានចង់តវ៉ាថាអង្គការអន្តរជាតិចោទប្រកាន់តែខាង សឺន សាន ឯខាង សក់ ស៊ុតសាខន គេហាក់ដូចជាមិនដឹងមិនឮដូចជាករណី ដែលគេឲ្យលោកឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ីង គន្ថុន រួចខ្លួន តែគេដាក់ទណ្ឌកម្មលើលោក ជា ឈុត និង លោក លីវ ណោ ជាភស្តុតាងស្រាប់ ។

នៅក្នុងសម័យនោះ ដោយសារលោកតា សឺន សាន ជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ លោកតាមិនបានយកវេទិកានៃសន្និសីទនេះ

[198] Son Sann, Speech delivedred at the International Conference, Human Rights For Cambodia, Survey and Prospects, Strasbourg, France, December 12-14, 1988.

ទៅវាយប្រហារឲ្យបានខ្លាំងក្លាលើអំពើប្រល័យពូជសាសន៍របស់ ប៉ុល ពត ទេ ព្រោះអាចនាំឲ្យទន់ខ្សោយ ឬ ប៉ះពាល់ដល់កម្លាំងប្រយុទ្ធប្រឆាំងកងទ័ពវៀតណាម នៅកម្ពុជា ។ ក៏ប៉ុន្តែ សិទ្ធិមនុស្សបានក្លាយជាមូលដ្ឋានទស្សនវិជ្ជានៃការតស៊ូប្រឆាំងរាល់អំណាចផ្តាច់ការរបស់រ.ជ. រ.ប.ខ. ។ នៅខែ តុលា ១៩៩១ ការគោរពសិទ្ធិមនុស្ស ក៏បានក្លាយទៅជាផ្នែកមួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសស្តីពីកម្ពុជា បន្ថែមលើផ្នែកផ្សេងទៀតដូចជាៈ ការបោះឆ្នោត យោធា រដ្ឋបាលស៊ីវិល មាតុភូមិនិវត្តន៍ និង ការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ។

# គណៈកម្មការយុត្តិធម៌

ជាមួយនឹងការងារផ្នែកសិទ្ធិមនុស្ស រ.ជ.រ.ប.ខ.ក៏យកចិត្តទុកដាក់ចំពោះផ្នែកយុត្តិធម៌ ។ អស់រយៈពេលច្រើនឆ្នាំ វិស័យយុត្តិធម៌មិនត្រូវបានយកចិត្តទុកដាក់ឡើយ ឬ ក៏គ្មានរូបរាងសោះក៏អាចថាបាន ។ លោកតា សឺន សាន បន្ទោសលោកអតីតអគ្គលេខាធិការ នាង ជិនហន ថាមិនបានគិតគូររៀបចំប្រព័ន្ធតុលាការ ឬ ការរៀបចំឲ្យមានច្បាប់ខ្លះៗនៅក្នុងជំរុំ ។ តាមពិតទៅ នៅក្នុងជំរុំដែលមិនស្ថិតក្រោមអធិបតេយ្យរបស់យើង ការរៀបចំប្រព័ន្ធតុលាការពិតជាមិនមែនងាយស្រួលទេ ។ ម្យ៉ាងទៀត កាលពីពេលដែលជំរុំមានទីតាំងនៅលើទឹកដីខ្មែរ ប្រធានជំរុំនីមួយៗធ្វើការគ្រប់គ្រងរបស់គេដូចជាស្តេចត្រាញ់យ៉ាងដូច្នេះដែរ ។ នៅខែ មីនា ១៩៩០ លោកតា សឺន សាន បានតែងតាំងរូបខ្ញុំឲ្យទទួលមុខនាទីជាសមាជិកគណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវខាងផ្នែកយុត្តិធម៌ បន្ថែមលើមុខងារជាអគ្គលេខាធិការទៀត[199] ។ ដូច្នេះនៅជំរុំសាយធូ ពួកយើងក៏ចាប់ផ្តើមរៀបចំឲ្យមានគណៈកម្មការ

[199] សឺន សាន, រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ, ក្រឹត្យលេខ ៩០/០៣/រជក, ធ្វើនៅតំបន់រំដោះ ថ្ងៃទី ១២ មីនា ១៩៩០ ។

យុត្តិធម៌មួយ ដោយយើងមិនបង្កើតសាលាកាត់ក្តីអ្វីទេ ។ គណៈកម្មការយុត្តិធម៌ទទួលពាក្យបណ្តឹង ធ្វើការស៊ើបអង្កេត ធ្វើសវនាការគូក្តី រួចធ្វើអនុសាសន៍ផ្តល់ដល់ទាំងដើមចោទ ទាំងចុងចម្លើយ ។ ដោយយើងគ្មានច្បាប់ យើងបានជាវក្រមព្រហ្មទណ្ឌ និង ក្រមរដ្ឋប្បវេណីថៃយកបកប្រែជាខ្មែរ និង ស្រង់យកចំណុចខ្លះៗមកប្រើ និង អនុវត្តតាមតាមករណីខ្លះៗដែលអាចអនុវត្តបាន ។ ពេលនោះ ខ្ញុំគិតថា ចំណាត់ការបែបនេះ ក៏គ្រាន់បើជាងគ្មានច្បាប់ទម្លាប់អ្វីទាំងអស់នោះដែរ ។ រឿងមួយដែលខ្ញុំចាំមិនភ្លេចនោះគឺ ក្រោយដែលបានបកប្រែក្រមព្រហ្មទណ្ឌថៃជាភាសាខ្មែររួចហើយ ប្រធានគណៈកម្មការយុត្តិធម៌នៅជំរុំដងរែក ដែលខ្ញុំចាត់ឲ្យបកប្រែក្រមនោះ ក៏ប្រកាសឲ្យប្រើច្បាប់ដោយខ្លួនឯង ដោយមិនចាំបាច់សុំច្បាប់ពីខាងលើឡើយ ។ ការនេះធ្វើឲ្យខ្ញុំមានការមិនពេញចិត្តយ៉ាងខ្លាំង ។

## មានបញ្ញវន្តចូលមកជួយ

ចាប់តាំងពីពេលដែលខ្ញុំចូលមកកាន់តំណែង ជាអគ្គលេខារ.ជ.រ.ប.ខ.មក ខ្ញុំក៏មានភ័ព្វសំណាង ដោយមានបញ្ញវន្ត និង អតីតមន្ត្រីដែលមានបទពិសោធន៍ចូលមកជួយធ្វើការផងដែរ ។ ក្នុងនោះមានលោកបណ្ឌិត ឡៅ ម៉ុងហៃ ដែលមានសញ្ញាប័ត្រថ្នាក់បណ្ឌិតសេដ្ឋកិច្ច ហើយបានលះបង់លាចាកក្រុមគ្រួសារនៅប្រទេសអង់គ្លេសមកចូលរួមជួយការងាររបស់យើង នៅឯការិយាល័យទីក្រុងបាងកក ។ លោក ឡៅ ម៉ុងហៃ ទទួលបន្ទុកជួយរៀបចំអត្ថបទទាំងអស់ជាភាសាអង់គ្លេស ។ នៅខែ មីនា ១៩៩០ គាត់ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការប្រតិបត្តិទទួលបន្ទុកខាងសេដ្ឋកិច្ច ។

បង ប៉ែន ថុល ដែលជាកូនប្រុសច្បងរបស់សម្តេច ប៉ែន នុត និង ជាបងរបស់សពបង ប៉ែន ថាល់ ក៏បានស្ម័គ្រចិត្តមកជួយធ្វើការនៅជាមួយពួកយើងឯទី

ក្រុងបាងកកដែរ ។ បង ប៉ែន ថុល ធ្លាប់កាន់តំណែងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នាសម័យសង្គមរាស្ត្រនិយមរបស់សម្ដេចសីហនុ ។ គាត់ត្រូវបានទទួលការតែងតាំងជាប្រធានខុទ្ទកាល័យនៃប្រធានរ.ជ.រ.ប.ខ. និង ប្រធានខុទ្ទកាល័យរដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ លោក ប៉ែន ថុល ជួយខ្ញុំក្នុងការងារផ្នែកការទូត និង ទំនាក់ទំនងអន្តរជាតិ ។ ម្យ៉ាងទៀត បង ប៉ែន ថុល ក៏ទទួលបន្ទុករៀបរៀងអត្ថបទខាងភាសាបារាំងដែរ ។ បន្ទាប់មកទៀត លោក សៀង ឡាប្រេស្ស ដែលជាអ្នកនិយាយព័ត៌មានតាមវិទ្យុសម្លេងស.រ.អា (VOA) ដ៏ល្បីល្បាញក៏បានស្ម័គ្រចិត្តមកជួយធ្វើការនៅជាមួយពួកយើងដែរ ។ នៅពេលគាត់ឡើងនិយាយជាសាធារណៈម្ដងៗ អ្នកស្ដាប់តែងលាន់មាត់ថា "អូ! សម្លេងស.រ.អា ចាប់ផ្សាយហើយ" ។

## ពួកយើងរកវិធីពង្រីកការអប់រំ នៅក្នុងជំរុំ

ជាមួយនឹងវិស័យសិទ្ធិមនុស្ស ក្រុមយើងក៏យកចិត្តទុកដាក់ក្នុងវិស័យអប់រំដែរ ។ យើងយល់ថាការអប់រំ និង ចំណេះវិជ្ជា ធ្វើឲ្យប្រជាពលរដ្ឋយើងមើលឃើញជើងមេឃវែងឆ្ងាយជាងពីបរិវេណជំរុំដែលត្រូវហ៊ុំព័ទ្ធដោយលួសបន្លានេះណាស់ ។ ដោយមានការឧបត្ថម្ភពីអង្គការមូនិធិអាឡឺម៉ង់ឈ្មោះហៅថា ខុនរ៉ាដ អាឌិនណៅអ៊ែរ (Konrad Adenauer Foundation) យើងបានរៀបចំជាមជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាមួយនៅជំរុំរិទ្ធិសែន ដើម្បីធ្វើការស្រាវជ្រាវអំពីប្រយោជន៍នៃព្រះពុទ្ធសាសនា នៅក្នុងសង្គមខ្មែរព្រមជាមួយមូលហេតុនៃការឡើងកាន់អំណាចរបស់ពួកខ្មែរក្រហម និង របបប្រល័យពូជសាសន៍ ។ ព្រះគ្រូ ពិន សែម ចៅអធិការវត្តរិទ្ធីសែន និង ភិក្ខុ ហេង មណីចិន្ដា បានជួយឲ្យគំរោងការនេះមានដំណើរការល្អបានលទ្ធផលគួរជាទីពេញចិត្ត ។ ភិក្ខុ ហេង មណីចិន្ដា ជាភិក្ខុនៅវ័យក្មេងតែខំយក

ចិត្តទុកដាក់ក្នុងការងារ ។ ពួកយើងបានតែងតាំងលោកឲ្យធ្វើជានាយកនៃមជ្ឈមណ្ឌលស្រាវជ្រាវនេះ ។

ជាមួយនឹងមជ្ឈមណ្ឌលស្រាវជ្រាវខាងព្រះពុទ្ធសាសនា មូនិធិ ខុនរ៉ាដ អាឌិន ណៅអ៊ែរ ក៏ជួយឧបត្ថម្ភសាលាហ្វឹកហាត់បច្ចេកទេសមួយ ដែលយើងបង្រៀនមុខវិជ្ជាខាងផ្នែកជាងជួសជុលរថយន្ត ជាងភ្លើងអគ្គិសនី និង ជាងអេឡិចត្រូនិច ។ ក្រៅពីនោះ យើងក៏មានបើកការបង្រៀនភាសាបរទេស ជាពិសេស ភាសាអង់គ្លេសជូនដល់ប្រជាពលរដ្ឋរស់នៅក្នុងជំរុំនេះផង ។ កម្មវិធីទាំងនោះ មានប្រជាប្រិយភាពណាស់ ។ អ្នកចេះភាសាបរទេសទាំងនោះ អាចមានលទ្ធភាពរកការធ្វើបាននៅក្នុងជំរុំជាមួយអង្គការក្រៅរដ្ឋាភិបាល ឬ អង្គការអន្តរជាតិនានាដែលកំពុងផ្តល់សេវានៅក្នុងជំរុំសាយធូ ។ អ្នកខ្លះទៀតជាប់តេស្តខាងភាសា អាចឲ្យគេចេញទៅរស់នៅប្រទេសទីបីដូចជា នៅកាណាដា ស.រ.អា ចក្រភពអង់គ្លេស ឬ នៅអូស្ត្រាលីបាន ។

មជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនា ក៏បានចេញផ្សាយនូវព្រឹត្តិប័ត្រមួយឈ្មោះ "ព្រះពុទ្ធសាសនា និង សង្គមខ្មែរ" ព្រមទាំងសៀវភៅឯទៀតទាក់ទងនឹងព្រះពុទ្ធសាសនា លទ្ធិប្រជាធិបតេយ្យ ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ខ្មែរដូចជាៈ ពលរដ្ឋវិជ្ជា លទ្ធិប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាជាដើម ។ល។ មជ្ឈមណ្ឌលនេះ ក៏បានបោះពុម្ពឡើងវិញនូវវចនានុក្រមខ្មែរសម្តេច ជួន ណាត និង វចនានុក្រមខ្មែរ-បារាំងរាប់ពាន់ក្បាលទៀតផង ។ តែជាការគួរឲ្យស្តាយឯកសារទាំងនោះ រួមទាំងវចនានុក្រមផង បានត្រូវឆេះអស់មួយចំនួនធំ នៅពេលតែប៉ុន្មានខែមុនការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន នៅក្នុងជំរុំសាយធូ ដោយអគ្គីភ័យដ៏ធំមួយ ។ ដោយសារមានការឧបត្ថម្ភពីអង្គការអន្តរជាតិ យើងក៏បន្ថែមកម្មវិធី

អប់រំឲ្យឡើងដល់កំរិតមធ្យមសិក្សា ទោះជាអង្គការយូអិនប្រូ និង អាជ្ញាធរថៃកំណត់តែត្រឹមការសិក្សាបឋមសិក្សាយ៉ាងណាក៏ដោយ ។

ចាប់តាំងពីមកដល់ទីស្នាក់ការរបស់យើង លោកបណ្ឌិត ឡៅ ម៉ុងហៃ ក៏បានផ្តល់យោបល់ឲ្យបង្កើតវិជ្ជាស្ថានមួយ ដើម្បីអប់រំហ្វឹកហ្វឺនក្របខ័ណ្ឌរដ្ឋបាលរបស់យើងសម្រាប់ពេលអនាគត ដែលប្រទេសកម្ពុជាយើងនឹងត្រូវការក្នុងពេលកសាងប្រទេសឡើងវិញ ។ ខ្ញុំ ក៏លើកគំនិតនោះទៅពិភាក្សាជាមួយលោកតា សឺន សាន ដែលគាំទ្រគំនិតនេះភ្លាម ។ ដូច្នេះ យើងក៏ចាត់ឲ្យលោកបណ្ឌិត ឡៅ ម៉ុងហៃ ទទួលបន្ទុកជានាយកនៃវិជ្ជាស្ថាននេះ ដែលមានឈ្មោះថា "វិជ្ជាស្ថានរដ្ឋបាលសាធារណៈ" ។ ក៏ប៉ុន្តែនៅពេលនោះ វិជ្ជាស្ថាននេះ មានតែនាយកម្នាក់ នៅមិនទាន់មានបុគ្គលិកដូចជាសាស្ត្រាចារ្យជំនាញ ដែលមានគុណសម្បត្តិត្រឹមត្រូវគ្រប់គ្រាន់ទាំងអស់ ។ ដើម្បីដោះស្រាយបញ្ហានេះ ខ្ញុំក៏បានស្នើសុំឲ្យអាជ្ញាធរថៃជួយដោះស្រាយបញ្ហាកង្វះខាតគ្រូឧត្តមសិក្សានេះ ។ នៅទីក្រុងបាងកក ខ្ញុំក៏បានទៅជួបលោកអនុប្រធានអគ្គនាយកដ្ឋានអង្គការអន្តរជាតិនៃក្រសួងការបរទេសថៃ ។ ខ្ញុំសុំជំនួយពីរាជរដ្ឋាភិបាលថៃ ដើម្បីអនុវត្តកម្មវិធីអប់រំផ្នែកឧត្តមសិក្សា ដោយម្យ៉ាងសុំបញ្ជូននិស្សិតខ្មែរឲ្យទៅរៀននៅសាកលវិទ្យាល័យថៃ ឬ ម្យ៉ាងទៀតសុំបញ្ជូនសាស្ត្រាចារ្យថៃឲ្យមកបង្រៀននិស្សិតខ្មែរនៅក្នុងជំរុំជនភៀសខ្លួន ។ យើងសុំជំនួយនេះ ដោយយើងប៉ាន់ប្រមាណឃើញសេចក្តីត្រូវការខាងធនធានមនុស្សរបស់ខ្មែរយើង នាពេលអនាគត ។ លោកអនុប្រធានអគ្គនាយកដ្ឋានថៃ ឆ្លើយយ៉ាងត្រង់មកខ្ញុំយ៉ាងដូច្នេះ៖ "ហេតុដូចម្តេចបានជាលោកសុំឲ្យប្រជាពលរដ្ឋលោក ដែលគ្រាន់តែជាជនភៀសខ្លួននោះឲ្យអាចរៀនដល់ឧត្តមសិក្សាបាន បើខ្លួនខ្ញុំផ្ទាល់ខ្ញុំមិនអាចទាំងឲ្យកូនរៀនដល់ថ្នាក់មធ្យមសិក្សាផង នេះមិនទាន់និយាយដល់អ្នកភូមិថៃ ដែលកំពុងរស់នៅក្បែរសាយធូ មិនអាចបញ្ជូនកូនចៅពួកគេ ទៅរៀននៅសាលាបឋមសិក្សា

ផងនោះ" ។ ដូច្នេះអាជ្ញាធរថៃ ក៏ទាត់ចោលសំណើរបស់ពួកយើង ។ ក៏ប៉ុន្តែពួកយើងក៏មិនបាក់ទឹកចិត្តអ្វីដែរ យើងនៅតែព្យាយាមរកមធ្យោបាយ ដើម្បីអនុវត្តកម្មវិធីឧត្តមសិក្សារបស់យើងតទៅទៀត ។ ដោយបានជំនួយហិរញ្ញវត្ថុពីមូលនិធិ ខុនរ៉ាដ អាឌិនណៅអ៊ែរ និង ក្រោយៗមក ក៏មានអង្គការក្រៅរដ្ឋាភិបាលឯទៀតជួយផងដែរមាន អង្គការកូអ៊ែរ និង សមាគមបារាំងឈ្មោះ អាហ្សៀ ពួ ឡឺ កាំបូដ (ធ្វើសកម្មភាពដើម្បីកម្ពុជា) យើងក៏សម្រេចដោះស្រាយបញ្ហានេះបាន ។ យើងបានសុំច្បាប់ឲ្យយុវជនបារាំងដែលជាសមាជិកសមាគមបារាំងខាងលើ ឲ្យចូលមកបង្រៀននៅក្នុងជំរុំពេលថ្ងៃ ហើយចេញទៅសម្រាកនៅភូមិថៃនៅក្បែរនោះឈ្មោះភូមិតាប្រាយ៉ានៅពេលយប់ ។ យើងជួលផ្ទះឲ្យអ្នកទាំងនោះស្នាក់នៅ និង ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ម្ហូបអាហារប្រចាំថ្ងៃផង ។ យុវជនបារាំងទាំងនោះសុទ្ធតែមានសញ្ញាប័ត្រចេញពីសាកលវិទ្យាល័យបារាំង ហើយមកស្ម័គ្រចិត្តបង្រៀននៅវិជ្ជាស្ថានរដ្ឋបាលសាធារណៈ តាមជំនាញរបស់គេដែលមានមុខវិជ្ជាដូចតទៅៈ ច្បាប់ សេដ្ឋកិច្ច នយោបាយ ទំនាក់ទំនង និង ជំនួយអន្តរជាតិ ។ ពួកគេបង្រៀនជាភាសាអង់គ្លេស បារាំង ឬ ដោយមានអ្នកបកប្រែមកជាភាសាខ្មែរ ។

តាមពិតទៅ យើងធ្វើដូច្នេះបានក៏ដោយសារតែឧត្តមបញ្ជាការកងទ័ពថៃបានចេញច្បាប់អនុញ្ញាតឲ្យយុវជនទាំងនេះ អាចចេញចូលជំរុំបានតែប៉ុណ្ណោះ ។ បើគ្មានច្បាប់នេះទេ យើងក៏ប្រហែលមិនអាចទទួលផលសម្រេចបានឡើយ ។ ដូច្នេះខាងទាហានថៃ ក៏បានជួយយើងខ្លះដែរ ទោះជារាជរដ្ឋាភិបាលថៃគ្មាននយោបាយជួយសម្រួលយើងក្នុងវិស័យអប់រំថ្នាក់ឧត្តមសិក្សានេះក៏ដោយ ។

លោក បណ្ឌិត ឡៅ ម៉ុងហៃ ខ្លួនឯងក៏ជួយបង្រៀនមុខវិជ្ជាច្បាប់សាធារណៈ ឬ ច្បាប់ធម្មនុញ្ញរដ្ឋបាលសាធារណៈ ផ្នែកសេដ្ឋកិច្ច និង ទំនាក់ទំនងអន្តរជាតិដែរ ។ បន្ថែមលើនេះ វិជ្ជាស្ថានរដ្ឋបាលសាធារណៈរបស់យើង ក៏បានឆ្លៀត

អញ្ជើញអ្នកការទូត នៃស្ថានទូតនានា ឬ មន្ត្រីអង្គការសហប្រជាជាតិ ដែលមកធ្វើទស្សនកិច្ចក្នុងជំរុំឲ្យជួយធ្វើបាឋកថា ឬ ផ្តល់បទអត្ថាធិប្បាយលើព្រឹត្តិការណ៍អន្តរជាតិណាមួយ ដែលអាចកើតមាននៅពេលនោះ ជូននិស្សិតនៃវិជ្ជាស្ថានស្តាប់ ។ ក្រៅពីនោះ វិជ្ជាស្ថានបានអញ្ជើញបុគ្គលិកអង្គការអន្តរជាតិ ដែលធ្វើការក្នុងជំរុំឲ្យមកថ្លែង ឬ បង្រៀនអំពីមុខជំនាញដែលគេមាន តាមរយៈការងារ ឬ ការសិក្សារបស់គេថែមទៀត ។ ជួនកាល យើងក៏ទទួលច្បាប់អនុញ្ញាតពីអាជ្ញាធរថៃអាចឲ្យនាំនិស្សិតទៅធ្វើទស្សនកិច្ចសិក្សា នៅប្រទេសថៃម្តងម្កាលក៏មានដែរ ។ តាមធម្មតាយើងរក្សាទុកកន្លែងឲ្យក្រុបខ័ណ្ឌរ.ជ.រ.ប.ខ. ដែលជាអ្នកទទួលខុសត្រូវតាមផ្នែកនានានៃជំរុំ ឲ្យចូលរៀននៅវិជ្ជាស្ថានរដ្ឋបាលសាធារណៈនេះ ។ ក៏ប៉ុន្តែក្រោយមកយើងទទួលយកសិស្សមធ្យមសិក្សា ដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សា (បាក់ឌុប) ឲ្យចូលរៀនឆ្នាំទីមួយនៃវិជ្ជាស្ថាន ។

ដើម្បីបំប៉នវិជ្ជាភាសាអង់គ្លេសដល់មន្ត្រីរបស់យើងៗ បញ្ជូនមន្ត្រីទាំងនោះទៅរៀនភាសានេះនៅប្រទេសថៃ ឬ ប្រទេសសឹង្ហបូរី ។ ខ្ញុំនៅចាំបានថាខ្ញុំបានបញ្ជូនយុវជនម្នាក់ពីភូមិសុខសាន្តឲ្យទៅរៀនភាសាអង់គ្លេសនៅសឹង្ហបូរី ។ យុវជននោះមិនចេះភាសាអង់គ្លេសមួយម៉ាត់សោះ ហើយធ្លាប់តែរស់នៅលើភ្នំ មិនដែលស្គាល់ទីក្រុងធំផង ។ បន្ទាប់ពីបានទៅរៀននៅសឹង្ហបូរីអស់រយៈមួយឆ្នាំ យុជននោះត្រឡប់មកវិញ និយាយភាសាអង់គ្លេសបាន តែសំនៀងដូចចិនសឹង្ហបូរីដូច្នោះដែរ ។ តាមបទបញ្ជារបស់អាជ្ញាធរថៃ យើងគ្មានសិទ្ធិអ្វីបញ្ជូនបុគ្គលិកមន្ត្រីរបស់យើងឲ្យទៅធ្វើសិក្ខាសាលា ឬ កម្មសិក្សា ឬ រៀនសូត្រនៅក្រៅជំរុំឡើយ នេះមិនទាន់និយាយដល់ការបញ្ជូនឲ្យទៅប្រទេសក្រៅផង ។ ដូច្នេះ បើយើងចង់បញ្ជូនមន្ត្រីយើងឲ្យចេញទៅបរទេស យើងលួចបញ្ចូលឈ្មោះមន្ត្រីនោះក្នុងបញ្ជីគណៈប្រតិភូដែលត្រូវទៅធ្វើទស្សនកិច្ចនៅបរទេស ដូចជាប្រទេសអាស៊ាន ជប៉ុន ប្រទេសនានា

នៅអឺរ៉ុប អូស្ត្រាលី និង សហរដ្ឋអាមេរិកជាដើម ។ យើងចេញលិខិតឆ្លងដែន និង សុំទិដ្ឋាការពីប្រទេសដែលត្រូវទៅរៀនសូត្រឲ្យដល់មន្ត្រីរបស់យើងទាំងនោះ ។ ពេលត្រឡប់មកវិញ យើងសុំទិដ្ឋាការពីក្រសួងការបរទេសថៃ ដែលជាធម្មតាអាចឲ្យគេរស់នៅលើទឹកដីថៃត្រឹមត្រូវតាមច្បាប់យ៉ាងតិចក៏បីខែដែរ ។ ដូច្នេះមន្ត្រីយើងមិនមែនជាជនអន្តោប្រវេសន៍ខុសច្បាប់ ឬ មិនមានការភ័យខ្លាចតម្រួតថៃចាប់ឃុំឃាំងដូចអ្នកភៀសខ្លួនឯទៀតឡើយ ។

## សកម្មជនប្រមូលកម្លាំងជាតិ

ទោះបីជាការចេញចូលជំរុំ មានការត្រួតពិនិត្យយ៉ាងតឹងតែងយ៉ាងណាក៏ដោយ ក៏នៅតែមានចលនាចេញចូលនេះខ្លះៗដែរ ជាពិសេសចំពោះអ្នករត់ពន្ធសកម្មជននយោបាយ និង ភ្នាក់ងារស៊ើបការណ៍ ។ នៅក្នុងជំរុំ ពួកយើងបំពាក់បំប៉នផ្នែកមនោគមវិជ្ជាមុននឹងបញ្ជូនចូលទៅក្នុងប្រទេសខ្មែរ ។ អ្នកទាំងនោះនឹងត្រូវបញ្ជូនឲ្យទៅធ្វើការជាមួយបណ្តាញផ្ទៃក្នុង ដោយនាំទៅជាមួយនូវឯកសារសម្រាប់ឃោសនាទៅជាមួយផង ។ បន្ទាប់ពីចូលទៅធ្វើការក្នុងប្រទេសបានមួយខែ ឬ ពីរខែមក ភ្នាក់ងារទាំងនោះនាំត្រឡប់មកជំរុំវិញនូវព័ត៌មានស្តីពីសភាពការណ៍នយោបាយ សេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា ដើម្បីឲ្យពួកយើងយកជាប្រធានបទនៃការឃោសនានយោបាយរបស់យើង ។ អ្នកខ្លះនាំមកនូវរូបថតនៃភូមិស្រុក ឬ សមាជិកផ្ទៃក្នុង ឬ នៃការប្រជុំសមាជិកគាំទ្រ ដែលគេបានទៅដល់ ឬ ដែលគេបានរៀបចំ ។ ភ្នាក់ងារខ្លះត្រូវទាហានថៃចាប់សួរចម្លើយ មុននឹងត្រូវបានអនុញ្ញាតឲ្យចូលមកក្នុងជំរុំវិញ ។ ភ្នាក់ងារខ្លះធ្វើការឲ្យរណសិរ្សយើងផង ធ្វើការឲ្យទាហានថៃខាងផ្នែកស៊ើបការណ៍ផង ។

នៅជំរុំសាយធូ យើងបានរៀបចំឲ្យមានក្រុមសកម្មជននយោបាយមួយក្រុម ដែលយើងឲ្យឈ្មោះថា "ប្រមូលកម្លាំងជាតិ" ។ ក្រុមនេះរើសអ្នកស្ម័គ្រចិត្តឲ្យធ្វើជាសកម្មជនបណ្តាញផ្ទៃក្នុងនៅក្នុងប្រទេស ។ អ្នកទាំងនោះត្រូវបានបំពាក់បំប៉នវិជ្ជាផ្នែកសិទ្ធិមនុស្ស ខ្លឹមសារនៃសេរីភាព ព្រមទាំងគោលការណ៍ និង កម្មវិធីនយោបាយរបស់រ.ជ.រ.ប.ខ. ។ ជាច្រើនដងក្នុងមួយខែៗយើងរៀបចំសន្និសីទ ឬ ការប្រជុំដើម្បីធ្វើការវាយតម្លៃអំពីការចរចាសន្តិភាព ក្នុងដំណោះស្រាយនយោបាយរបស់កម្ពុជាយើង ។ យើងតែងអញ្ជើញឥស្សរជនសំខាន់ៗមានអង្គទូតជាមិត្ត ឬ មន្ត្រីជាន់ខ្ពស់ក្នុងរណសិរ្សយើង ឲ្យមកធ្វើជាវាគ្មិនសំខាន់ៗក្នុងសន្និសីទ ឬ អង្គប្រជុំនោះ ។ ក្រុមនេះគាំទ្រយើងយ៉ាងសកម្មណាស់ ។

នៅពេលក្រោយៗមកទៀត អ្នកទោសនយោបាយដែលរួចពីការឃុំឃាំងនៅភ្នំពេញក៏ប្រមូលគ្នាមកនៅក្នុងជំរុំភាគច្រើននៅខាងក្រុម "ប្រមូលកម្លាំងជាតិ" នេះ ។ អ្នកខ្លះស្នាក់នៅមួយរយៈ រួចក្រោយពីបានទទួលទិដ្ឋាការ ក៏ចេញទៅរស់នៅឯប្រទេសទីបី ។ អ្នកមួយចំនួនទៀត បន្តរស់នៅជាមួយពួកយើងរហូតដល់ពេលមាតុភូមិនិវត្តន៍ ។

# លិខិតប្រចាំសប្តាហ៍របស់អគ្គលេខាធិការ

តាំងពីពេលដែលខ្ញុំឡើងកាន់តំណែង ជាអគ្គលេខាធិការរ.ជ.រ.ប.ខ.ភ្លាម ខ្ញុំចាប់ផ្តើមបោះពុម្ពផ្សាយលិខិតប្រចាំសប្តាហ៍របស់អគ្គលេខាធិការ ដើម្បីជូនដំណឹងពីសកម្មភាពការងារ និង ពីសភាពការណ៍នយោបាយ ការទូត និង យោធាជូនជាពិសេស ដល់សមាជិកដែលរស់នៅក្រៅប្រទេស ។ លិខិតប្រចាំសប្តាហ៍ក៏ត្រូវបញ្ជូនជាសម្ងាត់ មកដល់អ្នកគាំទ្ររបស់យើងនៅក្នុងប្រទេសដែរ ។ តាមធម្មតា ខ្ញុំតែងសរសេរបទអត្ថាធិប្បាយអំពីការរីកចំរើនរបស់យើង ទាំងនៅក្នុងជំរុំ

ក៏ដូចជាទាំងនៅលើការងារផ្នែកការទូត ។ កាលមុនខ្ញុំធ្វើជាអគ្គលេខាធិការ រណសិរ្សរបស់យើងក៏ធ្លាប់បោះពុម្ពផ្សាយព្រឹត្តិប័ត្រព័ត៌មាន ដើម្បីផ្សព្វផ្សាយសកម្មភាពជាភាសាខ្មែរ និង ជាភាសាអង់គ្លេសចែកជូនស្ថានទូតបរទេស និង សមាជិករ.ជ.រ.ប.ខ.នៅក្រៅប្រទេស ។ ក៏ប៉ុន្តែ ព្រឹត្តិប័ត្រនោះ ក៏ត្រូវផ្អាកការផ្សាយ ដោយខ្វះបុគ្គលិកផង ដោយខ្វះការចាត់ចែងការងារច្បាស់លាស់ខ្លះផង រហូតដល់ឈប់ចេញផ្សាយទាំងស្រុង បន្ទាប់ពីមានជម្លោះរវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន ។ ខ្ញុំសម្រេចចេញផ្សាយលិខិតប្រចាំសប្តាហ៍នេះ ដោយទទួលខុសត្រូវផ្ទាល់ខ្លួន មិនបាច់នៅរង់ចាំឲ្យមានគណៈកម្មការ ឬ ក្រុមការងារអ្វីទេ ព្រោះគណៈកម្មការ ឬ ក្រុមការងារនោះ ច្រើនប្រើពេលវេលាជជែកគ្នាច្រើនជាងការធ្វើការឲ្យចេញជាលទ្ធផលជាក់ស្តែង ។ តាមពិតទៅ សមាជិកសមាជិកានៅក្រៅប្រទេស គេរង់ចាំដំណឹងពីពួកយើងនៅបាងកកនេះណាស់ ។ កាលពីមុន គេទទួលដំណឹងម្តងម្កាលតាមសំបុត្ររបស់អគ្គលេខា ឬ អ្នកទទួលខុសត្រូវ ដែលគេស្គាល់ដោយចោះៗ មិនមានលក្ខណៈជាប់លាប់ឡើយ ។ ដូច្នេះ សំបុត្រប្រចាំសប្តាហ៍របស់ខ្ញុំ ក៏ទទួលបានប្រជាប្រិយភាព និង មានការគាំទ្រគួរជាទីគាប់ចិត្ត ។ បន្ទាប់ពីការចេញផ្សាយនៃសំបុត្រប្រចាំសប្តាហ៍នេះ ខ្ញុំបានទទួលជាហូរហែនូវការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីបងប្អូន នៅក្រៅប្រទេសទាំងនោះ ដែលមានការពេញចិត្ត និង កាន់តែមានជំនឿឡើងដល់រ.ជ.រ.ប.ខ. ។ ជាមួយនោះ ក៏លេចចេញនូវការច្រណែនពីសំណាក់អ្នកនៅជិតលោកតា សឺន សាន ខ្លះថា ខ្ញុំកំពុងខិតខំបង្កើតប្រជាប្រិយភាពសម្រាប់ខ្លួនតួទៅវិញ ក្រោយមក គេបន្ថែមថាខ្ញុំបង្កើតលទ្ធិតម្កើងបុគ្គលផង (Cult of personality) ។

# ប្រធានជំរុំ និង មេទ័ព

ជាទូទៅ ប្រធានជំរុំស៊ីវិលធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូរបស់គេ នៅក្នុងកងទ័ព ។ នៅពេលដែលគូទាហាន ដែលជម្មតាជាមេបញ្ជាការប្រចាំតំបន់ក្នុងជួរក.ជ.រ.ប.ខ. ត្រូវការបញ្ជូនយុទ្ធជនរបស់គេឲ្យចេញទៅប្រតិបត្តិការនៅក្នុងប្រទេស ប្រធានជំរុំស៊ីវិលត្រូវជួយឧបត្ថម្ភបន្ថែមលើអ្វី ដែលយុទ្ធជនទាំងនោះបានទទួលពីកងទ័ពរួចហើយ នូវស្បៀងអាហារ និង របស់របរប្រើប្រាស់ដែលគេមានដូចជា៖ អង្ករ ត្រីប្លាធូ ថ្នាំពេទ្យ សំពត់ប្លាស្ទីកជាដើម ។ល។ តាមពិតទៅ សាយធូក៏មិនខុសអ្វីពីទីកន្លែងសម្រាប់យុទ្ធជនត្រៀមរៀបចំខ្លួន មុននឹងត្រូវចេញទៅបំពេញបេសកកម្មយ៉ាងជ្រៅនៅក្នុងទឹកដីខ្មែរដែរ ។

លោក ឡាយ ខែក ធ្វើការជាដៃគូយ៉ាងជិតស្និទ្ធជាមួយលោក ខូ ឈា (ជួនកាលហៅថា ខូ ឈាន) ដែលជាមេបញ្ជាការតំបន់ ២០១ បន្ទាប់ពីតាម៉ាំងស្លាប់ទៅនៅក្នុងបេសកកម្មនាតំបន់ទន្លេសាប ។ ខ្ញុំចូលចិត្តធ្វើការជាមួយអស់លោកទាំងពីរនាក់នេះណាស់ ដោយសារនៅក្នុងអង្គភាពរបស់ពួកគេមានឯកភាពល្អ ហើយចេះជួយគ្នាទៅវិញទៅមកផង ។ អ្នកទាំងពីរបានបង្ហាញសមត្ថភាព និង ប្រសិទ្ធភាពក្នុងការដឹកនាំ ។ អ្នករស់នៅក្នុងជំរុំសម្លរឆ្ងាញ់ស្តាប់លោក ឡាយ ខែក ជានិច្ច ។ ខ្ញុំនៅចាំថាមានថ្ងៃមួយនោះ លោក ឡាយ ខែក ស្រែកគំរាមឲ្យចោរម្នាក់ទម្លាក់អាវុធចោល ហើយរត់ទាំងញាប់ញ័រ ដោយគ្រាន់តែឮសម្លេងគាត់ស្រែក ។ នៅឆ្នាំ ១៩៩០ យើងបានធ្វើការតែងតាំងលោក ឡាយ ខែក ជាប្រតិភូរងនៃគណៈកម្មាធិការប្រតិបត្តិរ.ជ.រ.ប.ខ.ទទួលបន្ទុកតំបន់រំដោះ ។

លោក ខូ ឈា ទទួលបានជោគជ័យនៅសមរភូមិជាច្រើន ដោយបានរំដោះទឹកដីមួយចំនួន ជាពិសេសតំបន់ប្រាសាទបន្ទាយឆ្មារ និង ថ្មពួក ។ ក្រោយពេល

ដែលកងទ័ពវៀតណាមដកចេញទៅ លោក ខូ ឈា បានមកតាំងទីបញ្ជាការរបស់គាត់នៅលើទឹកដីខ្មែរចម្ងាយប្រហែល ៣ ឬ ៤ គ.ម ពីជំរុំសាយធូ ។

នៅថ្ងៃទី ៣០ កញ្ញា ១៩៨៩ លោក ខូ ឈា បានដឹកនាំធ្វើការវាយប្រហារទៅលើកងទ័ពរដ្ឋកម្ពុជា នៅប៉ែកខាងលិច ដែលធ្វើឲ្យសភាពការណ៍នៅតាមជាយដែនខ្មែរ-ថៃមានការតានតឹងជាខ្លាំង ។ ពួកយើងមានការបារម្ភភ័យខ្លាចមានការបាញ់ផ្លោងតបមកវិញចូលក្នុងជំរុំសាយធូ ។ ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និង កុមារ សុទ្ធតែត្រូវបានឲ្យប្រុងខ្លួនត្រៀមជន្លៀសចេញទៅកន្លែងផ្សេង ។ ក៏ប៉ុន្តែជាភ័ព្វសំណាងល្អ ពុំមានហេតុការណ៍អ្វី ដែលនាំឲ្យមានការជន្លៀសចេញនោះទេ ។ មិនតែប៉ុណ្ណោះ លោក ខូ ឈា ថែមទាំងបានរំដោះបានទីតាំងប្រាសាទបន្ទាយឆ្មារផង ។ គាត់នាំមកទីបញ្ជាការជួរមុខរបស់គាត់នូវអាវុធយុទ្ធភ័ណ្ឌ ព្រមទាំងកូនទាហានរដ្ឋកម្ពុជាដែលរត់ចោលជួរមួយចំនួនផង ។

## យកបាយកញ្ចប់ទៅចែកខ្មែរគ្នាឯង ត្រូវយូអិនស្តីបន្ទោស

នៅថ្ងៃទី ៩ តុលា ១៩៨៩ ដែលជាថ្ងៃខួបកំណើតឆ្នាំទី ១០ របស់រ.ជ.រ.ប.ខ. លោក ឡាយ ខែក បានរៀបចំជាទិវាសាមគ្គី ដោយសុំឲ្យប្រជាពលរដ្ឋសាយធូជួយផ្តល់បាយកញ្ចប់យកទៅជូនជនរួមជាតិ ដែលទើបរត់មករួបរួមជាមួយពួកយើង ។ នោះជាការផ្តួចផ្តើមគំនិត ដែលនាំឲ្យមានសន្ទុះស្មារតីសាមគ្គីឡើងខ្ពស់យ៉ាងខ្លាំង ។ ពួកអ្នកជំរុំដែលសុទ្ធតែជាជនភៀសខ្លួននោះ បាននាំគ្នាដាំបាយរៀបចំវេចខ្ចប់ជាមួយម្ហូបម្ហា ដែលគេមានបន្តិចបន្តួច យកទៅផ្តល់ដល់ជនរួមជាតិ ដែលទើបមកចូលរួមជាមួយពួកយើងនាពេលនោះ ។ ពួកគេបានបង្ហាញធម៌សប្បុរស និង សេចក្តីអាណិតស្រឡាញ់ដ៏ជ្រាលជ្រៅដល់ជនរួមជាតិរបស់គេ ទោះធ្លាប់ជាគូបដិបក្ខគ្នាយ៉ាងណាក៏ដោយ ។ ក៏ប៉ុន្តែសប្បុរសធម៌ និង សាមគ្គីធម៌របស់អ្នកជំរុំ

សាយធូនោះ ក៏ត្រូវទទួលការស្តីបន្ទោសពីអង្គការយូអិនប្រូទៅវិញ ។ លោក តូស៊ីយូគី នីវ៉ា (Toshiyuki Niwa) បានសរសេរសំបុត្រផ្តន្ទាទោសការលួចនាំស្បៀងអង្ករបស់អង្គការយូអិនប្រូចេញក្រៅជំរុំ ដែលជាអំពើខុសពីអព្យាក្រឹតភាពនៃអង្គការនេះ ដែលមិនត្រូវផ្តល់ជំនួយដល់យោធានៃគ្រប់ភាគី ។ ជាទណ្ឌកម្ម លោក នីវ៉ា បានសម្រេចផ្អាកមួយរយៈនូវការឧបត្ថម្ភស្បៀងដល់មន្ត្រីរ.ជ.រ.ប.ខ. ដែលធ្វើការក្នុងជំរុំ និង ដល់ស្ត្រីម៉េម៉ាយដែលជាមេគ្រួសារ ។ តាមពិតទៅពួកយើងមិនបានយកចិត្តទុកដាក់ប៉ុន្មានឡើយ ចំពោះបទបញ្ជារបស់យូអិនប្រូ ព្រោះពួកយើងត្រូវខិតខំដោះស្រាយជួយសង្គ្រោះបន្ទាន់ ដល់ជនខ្វះខាតទាំងនោះ ទោះគេធ្លាប់ជាយុទ្ធជនរត់ចេញមកពីខាងក្នុងប្រទេសក៏ដោយ ។ ជាមួយនោះដែរ ខ្ញុំក៏បានទទួលស្គាល់ថាជំនួយរបស់យូអិនប្រូមួយចំនួន ក៏ត្រូវបានមន្ត្រីរដ្ឋបាលជំរុំលួចយកទៅផ្តល់ដល់យុទ្ធជន ដែលមានស្វាមីភក្តិដល់ពួកគេខ្លះៗដែរ ។

ទទួលបានដំណឹងថាមានទាហានរដ្ឋកម្ពុជាមកប្រមូលជាមួយ ខ្ញុំក៏មានចិត្តចង់ទៅជួបពួកគេភ្លាម ។ ខ្ញុំក៏ចេញដំណើរជាប្រញាប់ទៅជំរុំសាយធូ រួចឆ្លងដែនចូលទឹកដីខ្មែរ ត្រង់ចំណុចជំរុំដងរែកចាស់ ។ នៅពេលនោះ ខ្ញុំបានជួបយុទ្ធជនទាំងនោះដែលជាយុវជនក្មេងៗអាយុត្រឹម ២០ ឬ ៣០ ឆ្នាំ ដែលមិនមែនជាទាហានអាជីពផងទេ ។ ពួកគេទាំងអស់មានចំនួន ២១២ នាក់ ។ ក្នុងចំណោមយុវជនទាំងនោះ ក៏មាន ២ ឬ ៣ នាក់មកពីខេត្តព្រៃវែងរបស់ខ្ញុំដែរ ។ ខ្ញុំបង្ហាញខ្លួនចំពោះពួកគេ ក្នុងឋានៈជាអគ្គលេខាធិការរបស់រ.ជ.រ.ប.ខ. និង បានស្វាគមន៍ពួកគេក្នុងជួររ.ជ.រ.ប.ខ. ជាមួយនឹងការពន្យល់អំពីគោលនយោបាយរបស់យើង ដែលមានគោលដៅកសាងកម្ពុជាឯករាជ្យ និង ប្រឆាំងតបតចំពោះការវិលត្រឡប់មកកាន់អំណាចវិញនៃពួកប្រល័យពូជសាសន៍ ប៉ុល ពត ជាដាច់ខាត ។

# ដំណើរទៅតំបន់រំដោះ

បន្ទាប់មកខ្ញុំក៏មានគំនិតចង់ធ្វើដំណើរទៅទស្សនាតំបន់នានាដែលកងទ័ពរ.ជ.រ.ប.ខ.ទើបរំដោះបាន ហើយដែលពួកយើងហៅថា "តំបន់រំដោះ" ។ មែនទែនពួកយើង ត្រូវការជាចាំបាច់ឲ្យមានការរៀបចំជារដ្ឋបាលស៊ីវិល ឲ្យបានឆាប់រហ័សព្រោះទាំងនោះជាភស្តុតាងបង្ហាញពីសមត្ថភាពរបស់រ.ជ.រ.ប.ខ. ក្នុងការរំដោះទឹកដី ។ បើគ្មានតំបន់រំដោះដែលត្រូវរៀបចំឲ្យមានរដ្ឋបាលស៊ីវិល ធ្វើការគ្រប់គ្រងប្រជាពលរដ្ឋឲ្យបានត្រឹមត្រូវទេនោះ រ.ជ.រ.ប.ខ.ក៏គ្រាន់តែជាអង្គការតស៊ូដែលគ្មានទឹកដីអ្វីទាំងអស់តែប៉ុណ្ណោះគឺ គ្មានទម្ងន់សម្រាប់ការចរចាសន្តិភាពបន្តិចឡើយ ។ ម្យ៉ាងទៀត ទស្សនកិច្ចរបស់ពួកយើងអាចឲ្យយើងទៅពិនិត្យវាយតម្លៃពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋយើង ដែលរស់នៅក្នុងតំបន់ទាំងនោះ និង ជាឱកាសឲ្យយើងនាំជំនួយខ្លះទៅចែកជូនជនរួមជាតិយើងផង ។ យើងក៏បានកំណត់យកថ្ងៃទី ២៨ តុលា ១៩៨៩ ជាថ្ងៃចេញដំណើរ ។ ទស្សនកិច្ចរបស់យើងមានរយៈពេលពីរថ្ងៃទៅបន្ទាយឆ្មារគឺ ខ្ញុំត្រូវសម្រាកនៅភូមិបន្ទាយឆ្មារមួយយប់ ។ ផែនការធ្វើទស្សនកិច្ចនេះត្រូវបានធ្វើឡើងយ៉ាងសម្ងាត់បំផុត ។

ខ្ញុំរំភើបក្នុងចិត្តខ្លាំងណាស់ ចំពោះលទ្ធភាពដែលបានទៅមើលប្រាសាទបន្ទាយឆ្មារម្តងទៀត ដែលខ្ញុំធ្លាប់ទៅលេងម្តងរួចហើយកាលពីឆ្នាំ ១៩៨៣ ។ នៅពេលនោះ ខ្ញុំគ្រាន់តែទៅដល់តួប្រាសាទតែប៉ុណ្ណោះ មិនបានជួបប្រជាពលរដ្ឋទេ ហើយក៏គ្រាន់តែឃើញផ្ទះពីរ ឬ បីខ្នង ដែលគ្មានមនុស្សរស់នៅផង ។ នៅឆ្នាំ ១៩៨៣ នោះ ពួកយើងធ្វើដំណើរទៅបន្ទាយឆ្មារដោយថ្មើរជើង ។ លើកនេះយើងរៀបចំរទេះគោ ដើម្បីដឹកស្បៀង និង ជំនួយយកទៅចែកជូនអ្នកស្រុកនៅតំបន់នោះ ។ ពួកអ្នកមុខអ្នកការយើងនឹងត្រូវធ្វើដំណើរតាមម៉ូតូ ។

ព្រឹកព្រលឹមថ្ងៃទី ២៨ តុលា ១៩៨៩ យើងក៏ចាប់ចេញដំណើរតាមម៉ូតូគឺម៉ូតូ មួយមានគ្នាពីរនាក់ ។ ខ្ញុំជិះម៉ូតូជាមួយលោក ខូ ឈា ដែលជាអ្នកបើកបរ ។ សហការីឯទៀតក៏ជិះតាមគ្នាយ៉ាងនេះ រួមទាំងអស់មានម៉ូតូចំនួនប្រាំគ្រឿង ។ យើងទាំងអស់គ្នា ធ្វើដំណើរតាមផ្លូវរទេះមួយ ដែលមិនមែនជាការងាយស្រួលសម្រាប់ការបើកបរទោចក្រយានយន្តរបស់យើងឡើយ ព្រោះម្យ៉ាងពួកយើងត្រូវបើកកាត់ផ្លូវ ដែលមានភក់ដោយអន្លើៗ ម្យ៉ាងទៀតយើងត្រូវឆ្លងអូរមួយចំនួនផង ។ ដោយមានការលំបាកខ្លាំងពេក យើងក៏សម្រេចបើកកាត់ផ្លូវរទេះមួយទៀត ដែលអាចជាផ្លូវកាត់ផង តាមការអះអាងរបស់ទាហានដែលនៅយាមតាមតំបន់នោះ ។ តាមពិតទៅ ផ្លូវនេះជាផ្លូវថ្មើរជើងដែលយុទ្ធជនធ្លាប់ប្រើ ក៏ប៉ុន្តែមិនមែនជាផ្លូវសម្រាប់កង់ ឬ ម៉ូតូអាចប្រើប្រាស់បានឡើយ ។ ផ្លូវបត់ចុះបត់ឡើងឆ្លងកាត់វាលស្បូវ ឬ ព្រៃចកំពស់ស្មើរលិចក្បាល ក្នុងព្រៃដែលមានដើមឈើ ទំហំតូច និងមធ្យមជាច្រើនហូរហែជួយបាំងកំដៅថ្ងៃ ។ ដើមឈើខ្លះ ត្រូវដួលរលំកាត់ផ្លូវជាច្រើនកន្លែងដែលជាឧបសគ្គដល់ការធ្វើដំណើររបស់យើង ។ តាមផ្លូវ យើងប្រទះក្រុមទាហានរ.ជ.រ.ប.ខ.ដែលបោះទីតាំង ឬ ដែលដើរទៅមកនៅក្នុងព្រៃដោយរយៈៗ ។ នៅពេលពួកយើងសួរពួកគេ តើស្ថានភាពផ្លូវមានលក្ខណៈដូចម្ដេចដែរ? ទាហានទាំងនោះនិយាយថា "ផ្លូវស្រួលទេបង" ។ តាមពិតទៅ សម្រាប់ពួកគេ ផ្លូវនោះស្រួលមែន ព្រោះគេអាចដើរ ឬ លោតរំលងលើដើមឈើទាំងឡាយ ដែលនៅដួលដេកកាត់ផ្លូវនោះបាន តែចំពោះពួកយើងៗត្រូវបញ្ឈប់ម៉ូតូ រួចលើករំលងទើបអាចបន្តដំណើរទៅមុខទៀតបាន ។ ជាមួយគ្នានោះដែរ យើងត្រូវជិះម៉ូតូហោះឆ្លងអូរជាច្រើន ដែលអាចមានគ្រោះថ្នាក់រាល់ៗដង ។ ម្យ៉ាងទៀតខែ តុលា ជាខែមានភ្លៀងធ្លាក់ខ្លាំង ដូច្នេះនៅតាមកន្លែងខ្លះនៃផ្លូវនោះ ក៏មានជាំទឹកជាភក់ ឬ ល្បាប់ប៉ប៉ិកប៉ប៉ាច់ដ៏លំបាកក្នុងការធ្វើដំណើររបស់យើង ។ កន្លែងខ្លះទៀត ក៏រអិលស្ទើរចាប់

មិនឈ្នះ ។ កន្លែងខ្លះយើងត្រូវចុះជួយរុញម៉ូតូ កន្លែងខ្លះ យើងត្រូវចុះទាញម៉ូតូរបស់យើងដែលជាប់គាំងដោយដីភក់ ឬ ល្បាប់ ទើបអាចទៅមុខបាន ។

យើងធ្វើដំណើរអស់រយៈពេល ៦ ម៉ោង ដោយរាប់ទាំងការឈប់សម្រាកស្រស់ស្រូបអស់រយៈពេលមួយម៉ោងផង ។ យើងចាប់ផ្តើមជិះកាត់វាលស្រែខ្លះៗដែលនៅចន្លោះព្រៃ ។ វាលស្រែទាំងនោះជាសញ្ញាថាយើងកំពុងខិតចូលជិតដល់ភូមិអ្នកស្រុកហើយ ។ មិនយូរប៉ុន្មានដោយសារសម្លេងកងរំពងនៃគ្រឿងម៉ាស៊ីនម៉ូតូ អ្នកភូមិក៏នាំគ្នាចេញពីផ្ទះ លើកដៃស្វាគមន៍ពួកយើង ។ ទាំងក្មេង ទាំងចាស់ទាំងស្រីទាំងប្រុស អ្នកស្រុកចេញមកឈរនៅមុខផ្ទះ ទះដៃអបអរសោទរទទួលពួកយើងយ៉ាងសប្បាយរីករាយ ។ នៅទីបំផុត យើងក៏ចូលទៅសម្រាកក្នុងផ្ទះមួយដែលមានសភាពល្អគ្រាន់បើជាងគេ ។ គឺនៅក្នុងផ្ទះនោះហើយដែលពួកយើងជាពិសេសខ្លួនខ្ញុំផ្ទាល់ បានចូលមកទទួលទានដំណេកនៅយប់ទីមួយលើទឹកដីរំដោះ ។

នៅម៉ោងបីរសៀលពួកយើងក៏ចាប់ផ្តើមដើរពិនិត្យមើលសភាពការណ៍ទូទៅនៅក្នុងភូមិ ។ ជាដំបូង យើងជួបមនុស្សម្នាក់ជាអ្នកមុខអ្នកការនៅក្នុងភូមិដែលជាទូទៅគេ ហៅថាកាល់ម៉ាក្ស ព្រោះគាត់ទុកពុកមាត់ពុកចង្កាដូចលោកកាល់ម៉ាក្សដែរ ។ តាមពិត ឈ្មោះគាត់ពិតប្រាកដឈ្មោះ តាវ៉ា ។ តាវ៉ា មានរឿងរ៉ាវនិយាយប្រាប់យើងច្រើន ។ គាត់និយាយពីការរស់នៅរបស់គាត់តាមជំនាន់នយោបាយនីមួយៗ តាំងពីសម័យសង្គម សម័យសាធារណរដ្ឋ សម័យខ្មែរក្រហម និងសម័យរដ្ឋកម្ពុជា ។ តាវ៉ា មានអាយុជាង ៦០ ឆ្នាំ មកហើយ តែគាត់នៅមានសុខភាពមាំមួន ។ តាវ៉ា មានប្រពន្ធពីរដែលរស់នៅក្រោមដំបូលតែមួយ ។ ពេលពួកយើងទៅដល់ផ្ទះគាត់ៗស្រែកហៅប្រពន្ធ និង កូនៗ ទាំងអស់របស់គាត់ឲ្យចេញមកទទួលយើងយ៉ាងរាក់ទាក់បំផុត ។ ប្រពន្ធគាត់ទាំងពីរនាក់ នាំគ្នាយកអំបោះមកចងដៃពួកយើងតាមទំនៀមទម្លាប់អ្នកស្រុកបន្ទាយឆ្មារ ។ តាមទម្លាប់នៅខេត្តព្រៃវែង

របស់ខ្ញុំ ឪពុក ម្តាយ ឬ ចាស់ទុំនាំគ្នាយកអំបោះចងដៃកូនប្រុសកូនស្រី ឲ្យពរជ័យកូនទាំងនោះ តែនៅពេលមានមង្គលការតែប៉ុណ្ណោះ មិនដូចអ្នកនៅទីនេះទេ ។ តាប៉ា និង ប្រពន្ធ កូនរបស់គាត់ហៅពួកយើងថា "ឪៗ" តាមទម្លាប់របស់គេដែលចាត់ទុកពួកយើងជាអ្នកមានអំណាច ឬ អ្នកធំ ។

បន្ទាប់ពីសន្ទនាជាមួយ តាប៉ា និង ក្រុមគ្រួសារគាត់រួចហើយ ពួកយើងក៏នាំគ្នា ប្រញាប់ប្រញាល់ទៅមើលប្រាសាទបន្ទាយឆ្មារ កុំឲ្យយប់ងងឹតធ្លាក់មកដល់ទាន់ ។ ឈ្មោះបន្ទាយឆ្មារបានត្រូវបកស្រាយខ្លះៗថាបន្ទាយតូច ដោយយកពាក្យឆ្មារ (តូចណាស់ជាគោល) ។ អ្នកបុរាណវិទ្យាបានសាកល្បងពន្យល់ពីប្រវត្តិរបស់ប្រាសាទបន្ទាយឆ្មារ តាមការយល់ដឹងរបស់ពួកគេ ។ ដោយសារប្រទេសយើងកើតមានសង្គ្រាមញឹកញាប់ពេក យើងមានការលំបាកស្វែងរកឯកសារប្រវត្តិសាស្ត្ររបស់យើងខ្លាំងណាស់ ។ ឯកសារមួយចំនួន យើងអាចរកឃើញនៅឯទីបទីទៃៗ ។ ឯកសារមួយចំនួនធំ យើងរកបានអាស្រ័យដោយការសិក្សាស្រាវជ្រាវរបស់អ្នកប្រាជ្ញបារាំង ឬ អាចរកឃើញតាមសិលាចារឹក ។ ឯកសារមួយចំនួនទៀត យើងរកឃើញតាមរយៈអ្នកប្រវត្តិសាស្ត្រជនជាតិចិន ដែលបានមកដល់ប្រទេសកម្ពុជា ព្រោះថាប្រទេសចិនជាមហាប្រទេស ដែលបញ្ជូនទូតមកមុនគេ ។

# ប្រាសាទបន្ទាយឆ្មារ អាចរងគ្រោះដោយជនទុច្ចរិត

ប្រាសាទបន្ទាយឆ្មារ បានត្រូវកសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ ដែលជាមហាក្សត្រដ៏អង់អាចមួយព្រះអង្គក្នុងសម័យមហានគរ ដែលធ្វើឲ្យអារ្យធម៌ខ្មែរឡើងខ្ពស់ដល់កំពូលនៅចន្លោះសតវត្សទី ១២ និង ១៣ ។ បើប្រៀបធៀបទៅសភាពដែលខ្ញុំធ្លាប់ឃើញនៅឆ្នាំ១៩៨៣ តួប្រាសាទបានទទួលខូតខាតមួយចំនួន ។ ពួកអ្នកស្រុកនិយាយថា មានជនទុច្ចរិតមកគាស់យករូបចម្លាក់ ធ្វើឲ្យជញ្ជាំងប្រា

សាទបាក់បែកខូតខាត ។ ពួកយើងនាំគ្នាដើរលើគំនរថ្មដែលធ្លាក់គរ ទម្រាំយើងចូលដល់បរិវេណខាងក្នុងនៃប្រាសាទ ។ ខ្ញុំមានអារម្មណ៍ធូរស្រាលយ៉ាងខ្លាំងនៅពេលដែលឃើញបរិវេណខាងក្នុងនេះនៅល្អ និង រឹងមាំ ។ ប្រាសាទបន្ទាយឆ្មារក៏ដូចជាប្រាង្គប្រាសាទថ្មជាច្រើនទូទាំងប្រទេសកម្ពុជា បានត្រូវកសាងឡើងដោយបុព្វបុរសខ្មែរទុកជាមរតកឥតកាត់ថ្លៃបានឲ្យកូនចៅជំនាន់ក្រោយ ។ ស្នាដៃរបស់បុព្វបុរសខ្មែរទាំងអស់នោះ ក៏បានក្លាយទៅជាដួងព្រលឹងរបស់ប្រជាជាតិយើងរហូតដល់សព្វថ្ងៃនេះ ។ ដូច្នេះការជួយការពារអភិរក្សមរតកទាំងនេះ ជាភារកិច្ចដ៏ពិសិដ្ឋរបស់ខ្មែរម្នាក់ៗ ។ ប្រាំមួយឆ្នាំក្រោយមកគឺ នៅឆ្នាំ ១៩៩៥ ខ្ញុំបានទៅទស្សនាប្រាសាទបន្ទាយឆ្មារម្តងទៀត ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបំផ្លិចបំផ្លាញ ឬ គាស់រំលើង និង ការរត់ពន្ធរូបចម្លាក់នៃវត្ថុបូរាណដ៏មានតម្លៃមហាសាលទាំងនេះ ។ នៅក្នុងអង្គប្រជុំជាសាធារណៈមួយនៅស្រុកថ្មពួកក្នុងខេត្តបន្ទាយមានជ័យ ខ្ញុំបានលើកយកបញ្ហាការបំផ្លិចបំផ្លាញគាស់រំលើង និង រត់ពន្ធបុរាណវត្ថុមករំលឹកដាស់តឿនអាជ្ញាធរមូលដ្ឋាន និង សមត្ថកិច្ចទាំងអស់យកចិត្តទុកដាក់ចាត់វិធានការគ្រប់យ៉ាង ដើម្បីបំបាត់អំពើអវិជ្ជមានទាំងនោះ ដែលអាចនាំឲ្យរលំរលាយដល់ដួងព្រលឹងជាតិរបស់យើង ។

នៅពេលនោះ ខ្ញុំបានលើកយករឿងបន្ទាយលង្វែកមកបកស្រាយជូនអង្គប្រជុំស្តាប់៖ "ក្រោយពេលដែលព្រះអង្គបានវាយបណ្តេញទ័ពសៀមចេញពីអង្គររួចមក ព្រះបាទចៅពញាយ៉ាត បានលើករាជធានីមកក្រុងភ្នំពេញ ដោយបោះបង់ទីក្រុងអង្គរ ។ ក៏ប៉ុន្តែ បន្ទាប់មកនៅពេលព្រះអង្គច័ន្ទឡើងសោយរាជ្យ ព្រះអង្គបានលើករាជធានីពីភ្នំពេញមកតាំងនៅលង្វែក ព្រោះព្រះអង្គយល់ថា ទីនោះមានភូមិសាស្ត្រងាយស្រួលក្នុងការការពារ ប្រសិនបើមានការវាយលុកលុយពីបរទេស ។ ព្រះមហាក្សត្រអង្គនេះ បានចេញព្រះរាជបញ្ជាឲ្យដាំដើមឫស្សីព័ទ្ធជុំវិញបន្ទាយ

លង្វែក ។ នៅសតវត្សទី ១៦ សៀមបានលើកទ័ពលើកទីមួយ មកវាយបន្ទាយលង្វែក ។ ទ័ពបច្ចាមិត្រនេះ បានត្រូវទ័ពខ្មែរទប់ជាប់នៅក្នុងព្រៃឫស្សីអស់ជាច្រើនខែ ។ ដោយសារខ្វះស្បៀង ទ័ពសៀមដកថយទៅវិញ ។ ប៉ុន្មានឆ្នាំក្រោយមក ទ័ពសៀមលើកមកម្តងទៀត ដើម្បីវាយយកបន្ទាយលង្វែក ។ ពួកសៀម ដឹងថាបរាជ័យរបស់ខ្លួននៅលើកទីមួយនោះ ក៏ដោយសារតែព្រៃឫស្សីដែលជាឧបស័គ្គមិនឲ្យវាយចូលក្នុងបន្ទាយលង្វែកបាន ដូច្នេះលើកនេះ មេទ័ពសៀមរិះរកមធ្យោបាយបំផ្លាញព្រៃឫស្សីចោលជាមុនសិន មុននឹងវាយលុកចូល ។ ពួកបច្ចាមិត្តក៏បាញ់ទម្លាក់ទៅក្នុងព្រៃឫស្សីនូវប្រាក់ដួង ។ អ្នកស្រុកខ្មែរដែលមិនបានគិតដល់បញ្ហាសន្តិសុខរបស់ប្រទេសជាតិ ក៏នាំគ្នាទៅកាប់ឆ្ការព្រៃឫស្សី ដើម្បីទៅរើសយកប្រាក់ដួងទាំងនោះ ។ ក្រោយដែលព្រៃឫស្សីត្រូវបំផ្លាញដោយអ្នកស្រុកខ្មែរអស់ហើយ ទ័ពសៀម ក៏លើកគ្នាចូលមកវាយលុកយកបន្ទាយលង្វែកបានដោយជោគជ័យ ។ ចម្បាំងបន្ទាយលង្វែកនោះ ក៏ជាបរាជ័យដ៏អាម៉ាស់របស់ខ្មែរយើងនាសម័យនោះ ។ ឥឡូវនេះ យើងកំពុងជួបប្រទះហេតុការណ៍ប្រហាក់ប្រហែលគ្នាដែរ ។ ជនទុច្ចរិតបរទេស គេកំពុងបិតតម្លៃជាប្រាក់ដុល្លារ និង ប្រាក់បាតថៃនៅលើរូបចម្លាក់ សិលាចារឹក ឬ បូរាណវត្ថុ នៅតាមប្រាង្គប្រាសាទនានារបស់យើង ដើម្បីឲ្យខ្មែរដែលភ្លេចខ្លួនទៅគាស់រំលើងយកទៅលក់ឲ្យគេ ។ ដូច្នេះយើងត្រូវតែប្រុងប្រយ័ត្នខ្ពស់ ព្រោះថានៅពេលដែលមរតករបស់ដូនតាយើងបាក់បែកខ្ទេចខ្ទាំអស់ហើយ នោះព្រលឹងជាតិរបស់យើងក៏នឹងរលំរលាយមិនខានឡើយ ។ ដូច្នេះសូមមេត្តាជួយការពារប្រាសាទបន្ទាយឆ្មារនេះផង" ។

# នៅតំបន់រំដោះ ខ្ញុំប្រាប់អ្នកស្រុកឲ្យចាំមើលទង់ជាតិយើង

ព្រឹកស្អែកឡើងថ្ងៃទី ២៩ តុលា ១៩៨៩ ខ្ញុំបានទៅធ្វើអធិបតីនៃពិធីចែកអំណោយដល់ប្រជាពលរដ្ឋ ដែលជាឱកាសដំបូងអាចឲ្យខ្ញុំសំដែងមតិនៅលើទឹកដីនៃតំបន់រំដោះ ។ ខ្ញុំបានរំលឹកពីការខិតខំរបស់ចលនាយើង ក្នុងការតស៊ូដើម្បីឲ្យកម្ពុជាបានក្លាយជាប្រទេសសេរី ប្រកាន់លទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្សក៏ដូចជាការលើកតម្កើងប្រពៃណី និង វប្បធម៌ជាតិ ។ តាមពិតទៅ ខ្ញុំដឹងថាអ្វីដែលខ្ញុំនិយាយនៅពេលនោះ អ្នកស្រុកបន្ទាយឆ្មារមិនអាចយល់បានភ្លាមៗទេ ព្រោះបញ្ហារបស់អ្នកស្រុកគឺជីវភាពប្រចាំថ្ងៃរបស់គេជាងបញ្ហាប្រជាធិបតេយ្យ ឬ សិទ្ធិមនុស្ស ។ ក៏ប៉ុន្តែ នៅពេលនោះ ខ្ញុំបានជំរាបអ្នកស្រុកជារបៀបទស្សន៍ទាយដូចធ្លាប់និយាយច្រើនលើកច្រើនសារនៅជុំវិញសាយធូថា៖ "បងប្អូនចាំមើល នៅពេលណាដែលទង់ជាតិខៀវ ក្រហម មានប្រាសាទអង្គរកំពូលបីពណ៌សនៅចំកណ្តាលបានត្រូវបង្ហូតនៅភ្នំពេញ នៅពេលនោះប្រទេសយើងនឹងបានសុខសន្តិភាព យើងទាំងអស់គ្នានឹងសុខសប្បាយមិនខានឡើយ" ។ នៅពេលនោះ ខ្ញុំចង្អុលទៅទង់ជាតិដែលត្រូវបានបង្ហូតឡើងនៅពេលនោះ ។ តាំងពីរ.ជ.រ.ប.ខ.បានត្រូវបង្កើតឡើង ពួកយើងបានយកទង់ជាតិខៀវ ក្រហម ប្រាសាទអង្គរកំពូលបីនេះជាទង់ជាតិផ្លូវការរៀងរហូតមក ។ ទង់ជាតិនេះជាទង់ក្នុងសម័យសម្តេច សីហនុ កាលព្រះអង្គកាន់អំណាចមុនពេលមានសង្គ្រាមឆ្នាំ ១៩៧០ ។ នៅឆ្នាំ ១៩៩៣ ក្រោយការបោះឆ្នោតសាកលរួចមក ប្រទេសយើងក៏យកទង់នេះមកប្រើជាថ្មីឡើងវិញ ។ ដូច្នេះអ្វីដែលខ្ញុំទស្សន៍ទាយនៅបន្ទាយឆ្មារនោះ ក៏បានក្លាយជាការពិតមែននៅឆ្នាំ ១៩៩៣ ។

ខ្ញុំធ្វើដំណើរត្រឡប់ទៅទល់ដែនវិញ លាបន្ទាយឆ្មារ ដោយមនោសញ្ចេតនាសប្បាយរីករាយ ទោះជាការធ្វើដំណើរនោះ មានការហត់នឿយយ៉ាងណាក៏

ដោយ ។ តាមពិតទៅ ការធ្វើដំណើររបស់ពួកយើងអាចវាយតម្លៃបានថាៈ ១/៣ ជិះម៉ូតូ ១/៣ ជួយរុញម៉ូតូ និង ១/៣ ទៀតជួយទាញម៉ូតូ ។ រូបភាពដែលថតបានតាមវីឌីអូ (VDO) បង្ហាញពួកយើងជិះម៉ូតូកាត់ព្រៃព្រឹក្សា និង ទំនាក់ទំនងផ្ទាល់របស់ពួកយើងជាមួយប្រជាពលរដ្ឋនៅក្នុងតំបន់រំដោះ បានផ្តល់ផលល្អយ៉ាងខ្លាំងដល់ការងារខាងឃោសនា និង ទំនាក់ទំនងសាធារណៈរបស់ពួកយើង ។ ជាពិសេស រូបភាពទាំងនេះបានធ្វើឲ្យសមាជិករ.ជ.រ. ប.ខ.នៅក្រៅប្រទេសមានសន្ទុះទឹកចិត្តកើនឡើងទៀតជាអតិបរិមា ។ ទាំងអស់នេះ បានជាកត្តានាំនូវសេចក្តីសង្ឃឹមដល់ពួកគេ ក្តីសង្ឃឹមថានឹងបានវិលត្រឡប់ទៅមាតុប្រទេសវិញ នៅថ្ងៃណាមួយមិនខានគឺ វិលទៅប្រទេសខ្មែរដែលឯករាជ្យ និង មានសេរីភាព ។ ចំណុចល្អសំខាន់មួយទៀតនៃទស្សនកិច្ចរបស់ខ្ញុំនេះ បានសឲ្យឃើញថាខាងក្រុមលោកតាសឺន សាន ក៏មានកងទ័ព ដែលកំពុងប្រតិបត្តិការចូលទៅក្នុងប្រទេសដែរ ។ មែនទែន តាំងពីខែ ធ្នូ ១៩៨៥ គឺ នៅពេលដែលមានការបែកបាក់គ្នារវាងក្រុមលោកតាសឺន សាន និង ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន មក មានការសង្ស័យជាប្រចាំថា យុទ្ធជនរ.ជ.រ.ប.ខ.ប្រហែលជាគ្មានសមត្ថភាពធ្វើការប្រយុទ្ធឡើយ ។ វត្តមានរបស់ខ្ញុំនៅក្នុងតំបន់រំដោះក្នុងឋានៈជាអ្នកតំណាងលោកតា សឺន សាន បានជួយលើកកេរ្តិ៍ឈ្មោះរបស់លោកតាមួយកំរិតទៀត ព្រោះថាអស់រយៈពេលច្រើនឆ្នាំមកហើយ ដែលក្រុមប្រឆាំងបានបន្ទុះបង្អាប់លោកតាថាជាអ្នកដឹកនាំដែលមានតែឈ្មោះនៃចលនាតស៊ូនៅក្រៅប្រទេសមួយ គ្មានទំនាក់ទំនងជាមួយកងទ័ពណាមួយនៅលើទឹកដីខ្មែរឡើយ ។ តាមការឃោសនារបស់ក្រុមលោកឧត្តមសេនីយ សក់ ស៊ុត សាខន មានតែលោក សក់ ស៊ុតសាខន ទេដែលមានកងទ័ពបញ្ជាក្នុងឋានៈជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ។ ប្រាកដមែន លោកឧត្តមសេនីយ សក់ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ក៏ប៉ុន្តែមេបញ្ជាការជួរមុខមួយចំនួនដូច

ជាលោក ខូ ឈា ជាដើម បានរិះរកវិធីសាស្ត្រក្នុងការបំពេញបេសកកម្មរបស់ខ្លួនដោយឯករាជ្យម្ចាស់ការខ្លួនឯង ។ តាមធម្មតា គាត់ត្រូវរៀបចំទស្សនកិច្ចក្នុងតំបន់រំដោះ ជូនមេបញ្ជាការថ្នាក់លើក្នុងកងទ័ពជាមុនៗនឹងរៀបចំឲ្យខ្ញុំទៅជាន់ទឹកដីតំបន់រំដោះនោះ តែផ្ទុយទៅវិញលោក ខូ ឈា បានរៀបចំឲ្យខ្ញុំ ។ ទំនាក់ទំនងល្អរបស់ខ្ញុំផ្ទាល់ជាមួយមេបញ្ជាការកងទ័ពទៅជួរមុខ និង ការខិតខំបំពេញបេសកកម្ម ដើម្បីបំរើប្រជាពលរដ្ឋរបស់ខ្ញុំនៅទីបំផុតក៏បានទទួលផលជាវិជ្ជមាន ។ ក្រោយមកមិនយូរប៉ុន្មាន ខ្ញុំបាននិយាយរឿងរ៉ាវអំពីការធ្វើដំណើរទៅតំបន់រំដោះនេះ ជំរាបនាយទាហានជើងចាស់ធ្លាប់មានបទពិសោធន៍ក្នុងសមរភូមិ ដូចជាលោកវរសេនីយកេត រ៉េត ជាដើម ។ តារ៉េត បន្ទោសខ្ញុំថា ម្ដេចក៏ហ៊ានម្ល៉េះ ។ តាមធម្មតានាយទាហានអាជីពត្រូវរង់ចាំការបោសសំអាតមីនតាមផ្លូវឲ្យស្អាតជាមុនសិន ទើបគេហ៊ានធ្វើដំណើរចូលទៅតំបន់ទាំងនោះ ។

តាមពិតទៅ ជីវភាពរស់នៅនៅក្នុងជំរុំមិនមែនជាជីវភាព ដែលមនុស្សទូទៅតែងប៉ងប្រាថ្នាចង់ទៅរស់នៅនោះទេ ព្រោះថាអ្នករស់នៅក្នុងជំរុំពុំមានសិទ្ធិ និងសេរីភាពឲ្យបានពេញបរិបូរណ៌ដូចមនុស្សរស់នៅក្នុងប្រទេសរបស់ខ្លួនឡើយ ។ អ្នកភៀសខ្លួនទៅរស់នៅក្នុងជំរុំមួយភាគ រត់គេចពីសង្គ្រាម ស្វែងរកសេចក្ដីសុខមួយរយៈ រង់ចាំពេលវេលាល្អនឹងវិលចូលក្នុងប្រទេសវិញ មួយភាគទៀតអាចសង្ឃឹមរកផ្លូវភៀសចេញទៅក្រៅ ដើម្បីកសាងជីវភាពថ្មី ។ អ្នករត់ភៀសខ្លួន សុទ្ធតែប្រាថ្នាចង់បានជោគវាសនាឲ្យបានប្រសើរ ជាងកាលដែលគេរស់នៅក្នុងស្រុក ។ ដោយសារសប្បុរសធម៌របស់សហគមន៍អន្តរជាតិ ពួកជនទាំងនោះ បានទទួលការជួយឧបត្ថម្ភខាងផ្នែកស្បៀងអាហារ ទីជំរក សេវាសុខភាពខ្លះ និង ការសិក្សារៀនសូត្រខ្លះៗប៉ុណ្ណោះដែលមានត្រឹមលក្ខណៈជាជំនួយសង្គ្រោះបន្ទាន់ ។ ស្ថិតនៅក្នុងបរិបទបែបនេះ ទើបរ.ជ.រ.ប.ខ.ខិតខំបង្កើតបរិយាកាសនយោបាយឲ្យពួកគេយល់ដឹងថាជន

ភៀសខ្លួនមិនមែនជាមនុស្សអស់សង្ឃឹមនោះទេ ពួកគេអាចនឹងធ្វើឲ្យក្តីស្រមៃចង់បានសិទ្ធិ សេរីភាពក្លាយទៅជាការពិតបាន ។ ដោយសារការខិតខំស្វែងរកដំណោះស្រាយលើវិបត្តិនៅកម្ពុជា នៅទីបំផុតបងប្អូនជនភៀសខ្លួនមួយចំនួនធំបានវិលមកក្នុងប្រទេសវិញ រួចកសាងជីវិតថ្មីជាពលរដ្ឋនៃប្រទេសឯករាជ្យមួយ ដែលមានសន្តិភាព ។